**BMI0186**

# សម្ភាសន៍ជាមួយឈ្មោះ ហែម សាវិន ភេទស្រី អាយុ៥១ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ "ប្រធានកងតូច"

## រស់នៅភូមិប៉ុស្តិ៍ចាស់ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ

## សម្ភាសន៍ដោយៈ សោម ប៊ុនថន និង ចាន់ ប្រុញ

## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១

## ០១:០៨:៣៧

## ៤០ទំព័រ

ប៊ុនថនៈ អ៊ីចឹងជំបូងសុំស្គាល់ឈ្មោះរបស់អ្នកមីង? អ្នកមីងឈ្មោះអីដែរ?

សាវីនៈ ខ្ញុំដែលគេហៅនៅក្នុងភូមិនេះ ខំ ។

ប៊ុនថនៈ ចុះនៅក្នុងបញ្ជី?

សាវីនៈ ក្នុងបញ្ជី ហែម សាវីន ។

ប៊ុនថនៈ មីងអាយុប៉ុន្មានហើយសព្វថ្ងៃនេះ ។

សាវីនៈ ៥១ហើយ ។

ប៊ុនថនៈ ៥១ឆ្នាំ ។ មីងកើតនៅក្នុងភូមិឃុំអីដែរ?

សាវីនៈ យើងឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ កាលមុនហ្នឹងខេត្តបាត់ដំបង ។ កាលមុននោះ យើងនៅខេត្តបាត់ដំបង អត់មានខេត្តបន្ទាយមានជ័យអីទេ កាលពីសម័យនោះ ។

ប្រុញៈ ភូមិអីគេ?

សាវីនៈ ឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ។

ប្រុញៈ ភូមិអាស់?

សាវីនៈ ភូមិប៉ុស្តិ៍ចាស់ ។

ប៊ុនថនៈ ភូមិហ្នឹងពីដើមមកតែម្តង គេហៅមក?

សាវីនៈ ភូមិហ្នឹងពីសង្គមមកតែម្តង ពីខ្ញុំកើតមកហ្នឹងតែម្តង ។

ប៊ុនថនៈ អ្នកមីងមានបងប្អូនប៉ុន្មាននាក់?

សាវីនៈ បងប្អូន៤នាក់ ។

ប៊ុនថនៈ ប្រុសប៉ុន្មាន ស្រីប៉ុន្មានដែរអ្នកមីង?

សាវីនៈ ខ្វះស្លាប់ ទាំងអស់៦នាក់ ។

ប៊ុនថន៖ ៦នាក់?

សាវីន៖ ចាស៎! ប្រុស៤ ស្រី២ ។

ប៊ុនថន៖ ប្រុស៤ ស្រី ២ ហើយមិញហ្នឹង មីងថាស្លាប់ប៉ុន្មាននាក់?

សាវីន៖ ស្លាប់អស់១នាក់ នៅ៥នាក់ ។

ប៊ុនថន៖ ស្លាប់ជំនាន់ណាដែរអ្នកមីង?

សាវីន៖ ស្លាប់នៅជំនាន់នេះឯង ។

ប៊ុនថន៖ ក្រោយទេ ។

សាវីន៖ ចាស៎! ក្រោយសម័យយើងរត់៧៧-៧៨នេះឯង ។

ប៊ុនថន៖ បែក?

សាវីន៖ ចាស៎! ស្លាប់បងទី១ហ្នឹងឯង ។

ប៊ុនថន៖ ស្លាប់ពេលណាមីង ៨០ ក្រោយយើងហ្នឹងរត់៧៩ហ្នឹងមីង?

សាវីន៖ ហ្នឹងហើយ ដែលសម័យយើងហ្នឹងរត់ពន្ធទៅសំរោងអីហ្នឹង ។

ប៊ុនថន៖ ស្លាប់ដោយសារអីមីង?

សាវីន៖ កាលហ្នឹង គាត់ថាទៅវ៉ះទៅមើលជំងឺហ្នឹង ហើយទៅដល់ទៅជួបហ្នឹងពួក ថាកែៗហ្នឹងទៅ គេសម្លាប់ជាមួយហ្នឹងគ្នាទៅ ។ ដូចចោរប្លន់អីចឹងកាលហ្នឹងនោះ តែគាត់អត់មានអីទេ ។

ប៊ុនថន៖ ចុះមីងកូនទីប៉ុន្មានមីង?

សាវីន៖ ខ្ញុំកូនទី៦ ។

ប៊ុនថន៖ កូនទី៦ ។ កូនពៅ ។

សាវីន៖ ចាស៎!

ប៊ុនថន៖ ចុះបងប្អូនផ្សេងទៀតនៅជុំគ្នានៅព្រះនេតព្រះនេះ?

សាវីន៖ នៅព្រះនេតព្រះនេះ ៣នាក់ ទៅក្រៅហ្នឹង២នាក់ ។

ប៊ុនថន៖ ទៅស្រុកក្រៅ?

សាវីន៖ ហ្នឹងហើយ ។ ស្រុកណាវិញមីង?

ប៊ុនថន៖ នៅបារាំងនោះមួយ ហើយនៅអាមេរិកមួយ ។

ប្រុញ៖ គាត់រត់ទៅជំនាន់ ឬម៉េចទៅមីង?

សាវីន៖ គាត់រត់ទៅជំនាន់សម័ត៧៧-៧៨ហ្នឹង ។

ប្រុញ៖ បានរត់ចេញរួច ។

សាវីនៈ ហ្នឹងហើយបានរត់ចេញរួច ហើយដល់ពេលហើយទៅ គាត់ត្រលប់មករក បងប្រុសរបស់ខ្ញុំ បងថ្លៃហ្នឹងដែលគាត់រត់ទៅហ្នឹង បងទី១ បងទី២នោះ គាត់រត់ទៅសម័យនោះដែរ ហើយដល់ពេលនេះ គាត់មកយកកូនប្រពន្ធហ្នឹងទៅហើយ ។ តែកូនប្រពន្ធរបស់គាត់ហ្នឹង ស្លាប់អស់ហើយ នៅតែកូន១ ។ កូនទាំង៤របស់គាត់ហ្នឹងស្លាប់អស់ហើយ នៅតែកូនតែ១ទេ បានយកទៅជាមួយនឹង គាត់នៅលើភ្នំដងរែកនេះ ។

ប៊ុនថនៈ ខស្សរាហ៍មកលេងទេអ្នកមីង?

សាវីនៈ អត់ខស្សរាហ៍មកលេងទេ តាំងពីនោះមកមិនដែលមកទាល់តែសោះ ។

ប៊ុនថនៈ តែមានដែលទាក់ទងគ្នាទេ?

សាវីនៈ ទាក់ទងអី ខ្ញុំមិនសូវបានទាក់ទង អត់សូវបានទាក់ទងទេ ។

ប៊ុនថនៈ ចុះអ្នកមីងឪពុកម្ដាយនៅរស់ទេសព្វថ្ងៃហ្នឹង?

សាវីនៈ អត់ទេ! ស្លាប់អស់ហើយ ។

ប៊ុនថនៈ ស្លាប់ជំនាន់ណាអ្នកមីង?

សាវីនៈ ស្លាប់កាលសម័យប៉ុល ពត ៧៧ ។ ឪពុករបស់ខ្ញុំស្លាប់នៅឆ្នាំ៧៧ ។

ប៊ុនថនៈ ស្លាប់ដោយសារអីដែរមីង?

សាវីនៈ ដោយជំងឺ គាត់មនុស្សចាស់ហើយ ។

ប៊ុនថនៈ ចុះម្ដាយវិញអ្នកមីង?

សាវីនៈ ម្ដាយស្លាប់កាលនៅឆ្នាំ ២០០២ ។

ប៊ុនថនៈ បាទ!ស្លាប់ដោយសារជំងឺដែរ?

សាវីនៈ ចាំសដោយសារជំងឺរោគគាពាធមនុស្សចាស់ ។

ប៊ុនថនៈ ថ្នាក់ទី៧ពីសង្គមចាស់ ។

សាវីនៈ មកដក់ឥឡូវហ្នឹង?

ប៊ុនថនៈ មកដល់ឥឡូវហ្នឹង វាមកពីថ្នាក់ទី ១២ ១១ ១០ ៩ ៨

ប្រុញៈ ថ្នាក់ទី៥បច្ចុប្បន្ន

ប៊ុនថនៈ ១២ ១១ ១០ ៩ ៨ ៧ ថ្នាក់ទី៦ ។

ប៊ុនថនៈ នៅសាលាណាអ្នកមីង?

សាវីនៈ នៅសាលលាបឋមសិក្សាព្រះនេតព្រះដែលហ្នឹង ។

ប៊ុនថនៈ អ្នកមីងឈប់រៀនកាលឆ្នាំណាដែរទៅអ្នកមីង?

សាវីនៈ ខ្ញុំឈប់រៀននៅឆ្នាំណាអីចេះ ឆ្នាំ៧៤-៧៥ទេស ។

ប៊ុនថនៈ ក្រោយរដ្ឋប្រហាលន់ នល់?

សាវីនៈ ក្រោយរដ្ឋប្រហារ ម៉ាស្ទើរហ្នឹងរត់ប្រហានោះដែរ ។

ប៊ុនថនៈ ឆ្នាំ៧០ រដ្ឋប្រហារហ្នឹង?

សាវីនៈ អត់ទេ ក្រោយ៧៤ អីទេ ។

ប៊ុនថនៈ ម៉េចបានឈប់រៀនការហ្នឹង?

សាវីនៈ កាលហ្នឹងវាមានការវាយប្រហារគ្នាអីហ្នឹង ផ្ដើលខ្មែរក្រហមអីដែលហ្នឹង កាលនោះ ។ ភូមិនេះឆេះបន្ទក់គ្រាប់បែកអីមកហ្នឹង ប្លន់យកទ្រព្យសម្បត្តិអីអស់ ។

ប៊ុនថនៈ ខ្មែរក្រហម?

សាវីនៈ ហ្នឹងហើយខ្មែរក្រហម ។ អាសម័យយើងហ្នឹង ខ្មែរក្រហមហ្នឹង ៧៤-៧៥ហ្នឹង ។

ប៊ុនថនៈ អីចឹង ខ្មែរក្រហមហ្នឹងចាប់ផ្ដើមផ្លោងចូលហើយហ្នឹង?

សាវីនៈ ចូល! ចូលមកយកអីវ៉ាន់អីហ្នឹង គោក្របីអីហ្នឹង អត់មានសល់ទេ ។

ប៊ុនថនៈ អីចឹងចូលមកហ្នឹង ចូលមកនៅតែម្ដង ឬមួយចូលមកហើយមួយភ្លេតហើយចេញទៅវិញ?

សាវីនៈ ចូលមកហ្នឹងមួយភ្លេត ប្រហែលជាម៉ោង៣ ម៉ោង៤ជិតភ្លឺហ្នឹង ក៏ចេញទៅវិញ យករបស់របរអីហ្នឹង ហើយចេញទៅវិញ ។

ប៊ុនថនៈ ចុះមានស្លាប់ប្រជាជនអីទេអ្នកមីង?

សាវីនៈ គ្មានទេ កាលហ្នឹងនោះ ។

ប៊ុនថនៈ គ្រាន់តែឆេះផ្ទះទេ?

សាវីនៈ ទេ! កាលហ្នឹង អត់មានឆេះផ្ទះទេ កាលហ្នឹងចូលមកហ្នឹងមានស្លាប់ ២-៣នាក់អីទេ កាលហ្នឹងណាស់ ។ យើងរត់ឆ្លងផ្លូវនោះ ហើយវាឃើញអីចឹង វាវៃចោល វាស្មានថាអ្នកយកការណ៍អីចឹងណាស់ ។

ប៊ុនថនៈ ខ្មែរក្រហមហ្នឹងអ្នកវៃចោល?

សាវីនៈ ខ្មែរក្រហមអ្នកវៃ ។

ប៊ុនថនៈ វៃអ្នកភូមិរបស់យើងហ្នឹង?

សាវីនៈ វៃអ្នកភូមិ ។

ប៊ុនថនៈ គាត់នៅភូមិណាដែលកាលហ្នឹង?

សាវីនៈ ភូមិនេះឯង ។

ប៊ុនថនៈ ហ្នឹងហើយភូមិប៉ុស្តិ៍ចាស់ហ្នឹង ។ ពីណាដែលមីង? មានចាំឈ្មោះអីដែរទេមីង?

សាវីនៈ ចាំតើ បងប្អូនជីដូនមួយខ្ញុំ ។

ប៊ុនថនៈ គាត់ឈ្មោះអីមីង?

សាវីនៈ ឈ្មោះ នូ ស៊ុំ ។

ប៊ុនថនៈ នូ ស៊ុំ ។ ប៉ុន្មាន ស្លាប់ប៉ុន្មាននាក់កាលហ្នឹង?

សាវីនៈ កាលហ្នឹងជីងស្លាប់ប៉ុន្មានទេ ២នាក់ ឬមួយ៣នាក់ទេ ។ ដូចជានៅចាំតែម្នាក់បងជីដូនមួយរបស់ខ្លួនឯងហ្នឹង ។ គ្មានបានធ្វើបុណ្យអីស្រួលបួលទេកាលហ្នឹង ហើយទៅយកទៅកប់ទៅ ។

ប្រុញៈ កាលហ្នឹងឆ្នាំណាដែលកាលហ្នឹង? ប្រហែលជាឆ្នាំណា?

សាវីនៈ ប្រហែលជា៧៤-៧៥អីចឹង ។

ប្រុញៈ កាលហ្នឹង ខ្មែរក្រហមអត់ទាន់ចូលពេញលេញទេកាលហ្នឹង?

សាវីនៈ អត់ទេ ។

ប្រុញៈ អីចឹងនៅសម័យលន់ នល់ ។

សាវីនៈ ឆ្នាំ៧៣ ៧៤ កាលហ្នឹង កាលនោះឯង កាលហ្នឹង វាអត់មានទាន់ចាំច្បាស់នោះឯង ។

ប៊ុនថនៈ ចុះអ្នកភូមិនេះដល់ពេលចូលទៅ មានរត់ទៅណា ឬមួយភ័យអីទេ?

សាវីនៈ រត់មកនេះឯង តែដូនកាល ថាអត់នេះទៅ វាកៀយកទៅ កៀយកទៅក្រោមឯនោះ ។

ប៊ុនថនៈ កៀទៅណាវិញទៅ?

សាវីនៈ កៀទៅភូមិដូនឡិក ស្រែព្រៃនោះ អាតំបន់នោះ តំបន់ដែលគេរំដោះបាន ពួកខ្មែរក្រហមគេរំដោះបាន ។

ប៊ុនថនៈ អីចឹងគ្រួសាររបស់អ្នកមីងហ្នឹង មានគេកៀយកទៅទេ?

សាវីនៈ អត់ទេ អត់បានទៅទេ រត់ដុតទៅ គេចដុតទៅ ។

ប៊ុនថនៈ អីចឹងញាប់ទេ វាឆ្លក់ចូលហ្នឹង?

សាវីនៈ ស្មើរដែរ ចាំមិនសូវបានច្បាស់ដែរ ។

ប៊ុនថនៈ ខាងកងទ័ពលន់ នល់ហ្នឹងទៅណាវិញ?

សាវីនៈ នៅការពារហ្នឹង ហើយដល់ពេលផ្អើល គេវៃទៅហ្នឹង រត់ដែលហ្នឹង ពេលគេវៃព្រាវទៅរត់ដែល ហ្នឹង ។

ប៊ុនថន: បាទ!

សាវីន: កាលហ្នឹងទាហានលន់ នល់ ហ្នឹងនៅខាងកើតសាលាឃុំហ្នឹង ។

ប៊ុនថន: ជិតសាលាឃុំហ្នឹង? កាលមុនហ្នឹងមានបន្ទាយអីហ្នឹង?

សាវីន: ហ្នឹងហើយមានបន្ទាយ មានបន្ទាយ ដូចថាសាលារៀនដូចសាលាឃុំ សាលារៀននិង សាលឃុំហ្នឹងនៅបៀតគ្នាហ្នឹងណាស់ ។

ប៊ុនថន: បាទ!

សាវីន: សាលារៀននៅខ្ទះ នោះឯង ហើយសាលាឃុំនៅកន្លែងដែលធ្វើផ្សារ ។

ប៊ុនថន: អីចឹងទាហានលន់ នល់នៅប្រចាំការខាងហ្នឹង?

សាវីន: នៅខាងហ្នឹងផង ហើយនៅខាងជើងទៀត ។ នៅ២កន្លែង នៅសាលាឃុំផង នៅខាងជើងអីចឹងណាស់ ។ ដូចថាទាហានអីទេ ខ្ញុំមិនសូវស្គាល់ទេ ។

ប៊ុនថន: អីចឹងចាប់ពីហ្នឹងមក មីងឈប់បានទៅរៀនហើយ?

សាវីន: ចា៎ស! ឈប់ទៅរៀនរហូត ។

ប៊ុនថន: ចុះសាលាគេនៅបើកបង្រៀនទេ ឬមួយក៏យ៉ាងម៉េច?

សាវីន: គ្មានបង្រៀនទេ កាលហ្នឹងឈប់ហើយ ។

ប៊ុនថន: ពេលមីងឈប់ហ្នឹង សាលបិទទ្វារតែម្ដង?

សាវីន: សាលានៅរៀន១ឆ្នាំ ក្រោយទៀតហ្នឹង ផ្អើលគ្មានបានរៀនទាំងអស់គ្នាហ្នឹង ចប់៧៥-៧៦ ហ្នឹង គ្មានអ្នកណាបានរៀនបានសូត្រអីហ្នឹង ។

ប៊ុនថន: បាទ! ចុះក្រោយពីឈប់រៀនហ្នឹងមីងធ្វើអី មកផ្ទះឬមួយក៏?

សាវីន: កាលហ្នឹងរៀនហ្នឹង យើងមានបានធ្វើអី យើងនៅចល័ត ឈប់រៀនទៅផ្អើលៗទៅ រត់ពីព្រះនេត្រព្រះ អត់ហ៊ាននៅណា ផ្អើលរត់ទៅនៅឯបាត់ដំបងនោះ ។ ដល់ពេលគេថាឲ្យស្រុកកំណើតនៅឯណា ឲ្យយើងហ្នឹងត្រលប់មកវិញទៅណាស់ ហើយក៏ត្រលប់មកនៅស្រុកកំណើតវិញទៅ ។

ប៊ុនថន: ទៅបាត់ដំបងហ្នឹងមុនពេលខាងខ្មែរក្រហមចូលមកហើយឬនៅ? មីងទៅ?

សាវីន: ចូល..

ប៊ុនថន: មុនហ្នឹងទៀត?

សាវីន: អាកាលហ្នឹងសម័យហ្នឹងហើយដែលទៅ៧៤ គេផ្អើលគេអត់ហ៊ាននៅស្រុក ហើយរត់ទៅនៅបាត់ដំបង ហ្នឹង ។

ប៊ុនថន៖ ទៅនៅខាងណាវិញដែលមីងបាត់ដំបង?

សាវីន៖ បាត់ដំបងហ្នឹង កាលពីដើមហ្នឹង គេហៅបេនរ៉ុម៉ក់ដូនទាវ ពីដើមមិញ ពីសង្គម ។

ប៊ុនថន៖ នៅដូនទាវ? នៅទីរួមខេត្តតែម្តង?

សាវីន៖ នៅខេត្តបាត់ដំបងហ្នឹងឯង ។

ប៊ុនថន៖ អីចឹងទៅទាំងអស់គ្រួសាររបស់មីង?

សាវីន៖ ចាស! ទៅទាំងគ្រួសារទាំងអស់គ្នា ។

ប៊ុនថន៖ អីចឹង ទៅនៅទាល់តែខ្មែរក្រហមរំដោះបានហើយទើបមកវិញ?

សាវីន៖ ហ្នឹងហើយ! ទាល់តែខ្មែរក្រហមរំដោះបានទើបឲ្យត្រលប់មកវិញ ស្រុកកំណើតនៅឯណាហ្នឹងគេយកមកវិញទៅ ។ ថាមកទាំងអស់គ្នាហ្នឹង មិនបានឲ្យនៅក្នុងភូមិជាមួយគ្នាហ្នឹងទៀត គេជម្លៀសទៅនៅភ្នំកូនដំរី ។

ប៊ុនថន៖ កូនដំរី?

សាវីន៖ ហ្នឹងហើយ អត់មានបាននៅក្នុងភូមិយើងនេះទេ ។

ប៊ុនថន៖ ភ្នំកូនដំរី ឥឡូវនៅណា នៅភូមិ?

សាវីន៖ នៅនេះ!

ប៊ុនថន៖ នៅព្រះនេតព្រះយើងហ្នឹងដែរ?

សាវីន៖ ឃុំព្រះនេត្រ ស្រុកព្រះនេតព្រះហ្នឹងដែរ ។

ប៊ុនថន៖ ឆ្នាំអាវាលនេះទៅមីង?

សាវីន៖ ហ្នឹងហើយឆ្ងអាវាលនេះទៅបន្តិច ។ ដល់ពេលយើងទៅខាងនេះ ភ្នំកំបោរហើយ ។

ប៊ុនថន៖ ទៅនៅហ្នឹងមានគ្រួសាររបស់អ្នកមីងឬមួយមានគ្រួសារផ្សេងទៀត?

សាវីន៖ ប៉ុន្មានភូមិហ្នឹង គេឲ្យទៅនៅហ្នឹងតែម្តង ។

ប៊ុនថន៖ មានប៉ុន្មានភូមិដែលអ្នកមីង?

សាវីន៖ ភូមិប៉ុស្តិ៍ចាស់ ភូមិកណ្តាល ភូមិប៉ោយសំរោង គេឲ្យជម្លៀសទៅ ដើងវត្តអីហ្នឹងហ

ប៊ុនថន៖ ប៉ុស្តិ៍ចាស់ ប៉ោយសំរោង គេឲ្យទៅកូនដំរី?

សាវីន៖ ហ្នឹងហើយជម្លៀសទៅ គេឲ្យទៅនៅ ។

ប៊ុនថន៖ ខាងណាជម្លៀសទៅអ្នកមីង?

សាវីន៖ សម័យនោះឯងគេឲ្យទៅ ។

ប៊ុនថន៖ ខាងណាជម្លៀសអ្នកមីងទៅ? ចង់និយាយថាខាងណាអ្នកជម្លៀសអ្នកមីងទៅ ខាងភូមិឃុំ ខាងណា?

សាវីន៖ កាលហ្នឹង អង្គការគេឲ្យជម្លៀសទៅ កាលសម័យខ្មែរក្រហមហើយណាស់ ។

ប្រុញ៖ ឆ្នាំប៉ុន្មានដែរណាមីង?

សាវីន៖ ប្រហែលជា៧៦ ។

ប្រុញ៖ ឆ្នាំ៧៦ ។

សាវីន៖ អាហ្នឹងបានស្រាវជ្រាវជាមួយនឹងអ្នកចាស់ បានដឹងច្បាស់ ។

ប្រុញ៖ ជាទូទៅគេកំណត់ថាថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ជារបបខ្មែរក្រហមអីចឹងណាស់ ។ អីចឹងបានខ្ញុំចង់សួរបញ្ជាក់ថាជម្លៀសនៅឆ្នាំណា?

សាវីន៖ ៧៥-៧៦ហ្នឹងឯងជម្លៀសចេញពីភូមិហ្នឹងទៅ ។

ប៊ុនថន៖ អ្នកមីងទៅហ្នឹងគេបែងចែកយ៉ាងម៉េចដែរ?

សាវីន៖ បែងចែកនារីយុវជន ។ នារីទៅគេឲ្យទៅស្រែអីទៅ ។

ប៊ុនថន៖ បែងចែកឲ្យចូលកង?

សាវីន៖ ហ្នឹងហើយបែងចែកឲ្យចូលកង ជាក្រុមចល័តទៅ ចេញនេះចេញជាក្រុមចល័តហើយ ។

ប៊ុនថន៖ ប៉ុន្តែអ្នកមីងមានបានចូលទេ?

សាវីន៖ កាលហ្នឹងអត់ទាន់បានចូលទេ ទាល់តែ៧៦ ។ ទាល់ឆ្នាំ៧៦ ជិត៧៧ ទាល់តែធ្វើស្រែអីរួចទើប បានគេឲ្យជីកទំនប់លើកប្រលាយនោះហើយ ។

ប៊ុនថន៖ អីចឹងកាលនោះមីងនៅធ្វើការធម្មតាទេ?

សាវីន៖ ហ្នឹងហើយ ។

ប៊ុនថន៖ នៅដកស្ទូង អត់ទាន់មានធ្វើការជាកងទេ?

សាវីន៖ ហ្នឹងហើយអត់មានទាន់បែងចែកទេ ទើបតែដំបូងហ្នឹងអត់ទាន់ទេ ទាល់តែក្រោយមកហ្នឹងទើបគេធ្វើការបែងចែកជាចល័តនារីយុវជនទៅ ។

ប៊ុនថន៖ មីងទៅហ្នឹងបានប៉ុន្មានខែបានគេធ្វើការបែងចែក?

សាវីន៖ មិនដឹងប៉ុន្មានខែទេ ខ្ញុំអត់ចាំទេ ។ បើសួរមនុស្សដែលគាត់ចាស់នេះ អាចចាំបានច្បាស់ថាខែណាឆ្នាំណាអីទេ គាត់ ចាំច្បាស់ ។ ហើយខ្ញុំហ្នឹងវានៅស្ទើរ ។

ប្រុញ៖ អ្នកមីងអាយុប៉ុន្មានដែលកាលនោះ?

សាវីន៖ ប្រហែលជា១៥-១៦អីហ្នឹង ។

ប្រុញៈ	កាលទៅភ្នំកូនដំរីហ្នឹង ។

សាវីនៈ	ហ្នឹងហើយ កាលហ្នឹង អាយុប្រហែលជា១៥ឆ្នាំទេ ។

ប៊ុនថនៈ	ទៅកូនដំរីហ្នឹងធ្វើអីខ្លះ?

សាវីនៈ	ទៅកូនដំរីហ្នឹងអត់សូវយូរប៉ុន្មានទេ ទៅស្រែសបានយូរ ។ បើជម្លៀសពីកូនដំរីនោះ ទៅនៅស្រែះ ។ ទៅនៅស្រែសបានយូរបាន៤-៥ខែហើយដឹង ។ ហើយទៅនៅនោះ រួចបានគេឲ្យចេញមកនៅប៉ោយព្រីងយើងហ្នឹង នៅក្នុងព្រៃអាដើងភ្នំយើងហ្នឹងទៀត ណាស់ ២-៣កន្លាក់ណាស់ ។ មិនមានមកនៅក្នុងភូមិរបស់យើងហ្នឹងវិញទេ អាហ្នឹង ទាល់តែនៅក្នុងព្រៃហ្នឹងឲ្យចប់ ដែលថាចប់ហើយហ្នឹង ដែលថាពួកវៀតណាមរំដោះហើយ ហ្នឹង បានយើងបានមកផ្ទះរបស់យើងហ្នឹងវិញ ។

ប៊ុនថនៈ	ទៅនៅស្រែសហ្នឹងមីងធ្វើអីវិញ?

សាវីនៈ	ធ្វើស្រែដែរហ្នឹង ។

ប៊ុនថនៈ	ធ្វើស្រែ?

សាវីនៈ	ហ្នឹងហើយធ្វើស្រែធ្វើចំការអីហ្នឹង ។

ប៊ុនថនៈ	តែធ្វើរួម?

សាវីនៈ	ចាស! ធ្វើជារួមទេ អត់មានធ្វើឯកជនទេ ធ្វើច្រើន អីចឹងចូលរួមហើយ ។

ប៊ុនថនៈ	កាលហ្នឹងមានអ្នកថ្មីគេជម្លៀសមកទេ ដូចជាអ្នកមកពីខេត្តផ្សេងៗអីណាស់?

សាវីនៈ	អត់មានទេ អត់ទាន់មានទេ ។ អ្នកជម្លៀសមកហ្នឹង មាននៅក្នុងភូមិនេះ ។ ដល់ពួកខ្ញុំ ហ្នឹង ប្រជាជនចាស់ ដែលហៅប្រជាជនចាស់ហ្នឹង គេឲ្យជម្លៀសទៅនៅនោះ ទៅនោះ ហ្នឹងនៅក្នុងព្រៃនោះ នៅភូមិ......

ប៊ុនថនៈ	ប៉ោយព្រីង ។

សាវីនៈ	ប៉ោយព្រីង ប៉ោយតាប៉ែន ទៅឯជើងភ្នំនោះ ។ គេឲ្យរកពាំងមកនៅខាងជើងភ្នំនេះ ដល់ភូមិដក់ពរ យើងចេញមកថ្នល់នេះវិញ ។ គេឲ្យពួកខ្ញុំហ្នឹងនៅ ។ ហើយក្រោយ ទៀត បានពួករំដោះ ១៧ មេសា គេឲ្យមកនៅហ្នឹងនេះ ពួកភ្នំពេញ ពួកអារីក្សត្រ ពួកអីមកនៅនេះច្រើនដែរនោះ ។

ប៊ុនថនៈ	នៅ?

សាវីនៈ	នៅហ្នឹងនេះ គេធ្វើផ្ទះ ខ្ទមឲ្យច្រើនដែលនោះ ។ គេធ្វើខ្ទមតូចៗគេធ្វើឲ្យនៅហ្នឹងនោះ ។

ប៊ុនថនៈ	អីចឹង មីងនៅ....

សាវីនៈ នៅភ្នំស្រែសហ្នឹង!

ប៊ុនថនៈ នៅស្រែសហ្នឹង អត់ទាន់មានកងទេ នៅធ្វើរួម? ដល់ប៉ោយព្រឹងហ្នឹង មានកងរួមហើយឬនៅ?

សាវីនៈ ចែកហើយ ចេញកងចល័តអីហើយអស់ហើយហ្នឹង ចេញចល័តអស់ហើយអត់មានបាននៅផ្ទះអីទេ ឪពុកម្ដាយទៅធ្វើការផ្សេងទៅ ហើយកុមារទៅធ្វើតាមកុមារទៅ នារីយុវជនគេចែកគ្នា អានេះទៅនោះទៅ គេចាត់ចេញជាប្រធានភូមិ គេត្រូវការទៅណា គេចាត់ទៅណាស់ ដូចថាគេថាអានេះឯង គេស្នើរទៅធ្វើការទៅណាស់ ទៅណាហ្នឹងគេចេញទៅធ្វើការទៅណាស់ ។

ប៊ុនថនៈ នៅស្រែសហ្នឹងដូចថាមានយ៉ាប់យឺនអីទេ ការងារ?

សាវីនៈ ការងារហ្នឹង វាមិនពិបាកធ្វើរួមអីចឹង វាមិនពិបាកប៉ុន្មានទេ ។

ប្រុញៈ ធ្វើអីគេមីងនៅស្រែស?

សាវីនៈ ធ្វើស្រែហ្នឹង ។

ប្រុញៈ ធ្វើស្រែ ។

សាវីនៈ ធ្វើស្រែចំការអីដែរហ្នឹង ។ មានអីទេ មានតែស្រែចំការហ្នឹងឯង គ្មានអីទេ ដល់ក្រោយចល័តហ្នឹងបានពិបាកតិច ។

ប៊ុនថនៈ ដល់ពេលមកដល់ប៉ោលព្រឹងហ្នឹងបានគេបែងចែក?

សាវីនៈ គេបែងចែកតាមភូមិតាមក្រុមរបស់គេទៅ ។

ប៊ុនថនៈ កាលហ្នឹង មីងចូលក្រុម?

សាវីនៈ ចូលក្រុមនារីយុវជនហើយ ។

ប៊ុនថនៈ នារីយុវជន! ប៉ុន្មាននាក់ម៉ាក្រុមរបស់មីង?

សាវីនៈ ទេកាលហ្នឹង មិនដឹងថាប៉ុន្មាននាក់ទេកាលហ្នឹង ។

ប៊ុនថនៈ មីងនៅកងតូចឬមួយកង ...?

សាវីនៈ កាលហ្នឹង អត់ទាន់ដឹងកងតូចកងធំទេ នៅក្នុងភូមិអត់ទាន់បែងចែកទេ ទាល់តែចេញទៅចល័តបានគេបែងចែកជាកងជាក្រុម ។

ប៊ុនថនៈ មីងនៅជាមួយនឹងពីណាកាលហ្នឹង?

សាវីនៈ ទៅនោះ តាម៉ង តាភ៊ាល់ ចល័តតាភ៊ាល់ គេហៅចល័តតាភ៊ាល់ ។

ប៊ុនថនៈ ចល័តតាភ៊ាល់ ចល័តតំបន់ទេមីង?

សាវីនៈ ហ្នឹងហើយ ចល័តតំបន់ ។

ប៊ុនថនៈ មឺងនៅចល័តំបន់?

សាវីនៈ ហ្នឹងហើយ គេឲ្យសែងទៅតាមភូមិហ្នឹង នារីប៉ុន្មាន យុវជនប៉ុន្មាន គេឲ្យចេញទៅ គេបែកផ្នែកគ្នាទៅ អត់បានទៅជាមួយនឹងគ្នាទេ ។ អ្នកខ្លះទៅចល័តណាទៅ អ្នកខ្លះ អត់មានបាន ទៅជាមួយនឹងគ្នារួមគ្នាទេណាស់ ស្រេចតែគេចាត់ទៅ ។

ប្រុញៈ តាវ៉ាល់អ្នកចាត់ចែងផ្ទាល់តែម្ដងឬយ៉ាងម៉េច?

សាវីនៈ ទេ ទៅដល់នោះ តាវ៉ាល់គាត់អ្នកចាត់ចែងផ្ទាល់តែម្ដង ។ គេចល័តយើងហ្នឹងទៅ ដូចថាប្រមូលពីតាមស្រុក ឃុំទៅ គេចល័តរាប់ពាន់រាប់ម៉ឺននាក់នោះ ដេកធ្វើរោងនៅនោះ ធ្វើរោងដេក ។

ប្រុញៈ គេហ្នឹង គេចាត់តាំងឲ្យអ្នកមីងធ្វើអីគេ?

សាវីនៈ កាលហ្នឹង ខ្ញុំប្រធានកងតូច ។

ប៊ុនថនៈ ប្រធានកងតូច ។

សាវីនៈ ចេះអក្សរតិចៗហ្នឹងគេឲ្យធ្វើ សរសេរអក្សរមិនទាន់ត្រូវផងហ្នឹង ។

ប៊ុនថនៈ ប្រធានកងតូចឬកងធំមីងកាលហ្នឹង?

សាវីនៈ មិនដំបូងគេឲ្យធ្វើកងតូច តែធ្វើទៅ ក្រោយមកហ្នឹងគេឲ្យធ្វើកងធំ ។

ប្រុញៈ កាលហ្នឹង គ្រប់គ្រងមនុស្សប៉ុន្មាននាក់ដែរកាលហ្នឹង?

សាវីនៈ ១០០នាក់ ។ កងធំ១០០នាក់ កងតូច៣០នាក់ ។

ប៊ុនថនៈ អាហ្នឹង គេជ្រើសរើសយ៉ាងម៉េចដោយសារឃើញយើងហ្នឹងធ្វើការងារសកម្ម?

សាវីនៈ ធ្វើការងារសកម្ម ធ្វើពលកម្មសកម្មទៅហ្នឹង គេឲ្យយើងធ្វើ មុនដំបូងកងតូចដែរ តែក្រោយមកធ្វើការល្អទៅ គេឲ្យឡើងជាប្រធានកងធំទៅ. ។

ប៊ុនថនៈ ពេលនោះ គាត់ដឹកនាំកម្លាំងធ្វើនៅខាងណាវិញ?

សាវីនៈ ធ្វើនៅវាលស្រែសយើងហ្នឹងឯង ។

ប៊ុនថនៈ វាលស្រែស ។

សាវីនៈ ចំនៅត្រង់នោះឯង ។

ប៊ុនថនៈ អីចឹងអាហ្នឹងនៅកំបោរស្រែសទេមីង?

សាវីនៈ ទំនប់កំបោរស្រែស?

ប៊ុនថនៈ ចុះអាហ្នឹងខុសប៉ោយព្រីងម៉េចទៅ?

សាវីនៈ ទេអាហ្នឹងពេលជម្លៀសទៅ គេឲ្យឪពុកម្ដាយហ្នឹងទៅនៅភូមិនោះ ទៅនៅប៉ោយព្រីង ហ្នឹងយើងចេញចល័តទៅណា ទៅទៅ ។ ភូមិរបស់យើងនៅនោះឯង បើសិនយើងចង់ទៅលេង ភូមិអីនោះឯង គេឲ្យទៅលេងទៅ ភូមិរបស់យើងនៅនោះឯង ងត់មាននៅនេះទេ ។

ប្រុញៈ ដឹកនាំក្រុមទៅហ្នឹងទៅធ្វើការនៅកំបោរស្រែស?

សាវីនៈ ហ្នឹងគេហៅទំនប់កំបោរស្រែស ។

ប្រុញៈ នៅប៉ោយព្រីងហ្នឹង អត់មានធ្វើទំនប់អីទេ?

សាវីនៈ អត់មានទេ ។ អត់មានធ្វើទេ គេឲ្យយើងហ្នឹងចល័តចេញទៅហ្នឹង ។

ប្រុញៈ បាទ! យល់ ។

សាវីនៈ ហ្នឹងហើយ ។

ប៊ុនថនៈ អីចឹងមីងដឹកនាំកម្លាំងទៅស្រែសតែម្ដង?

សាវីនៈ នៅស្រែស អត់បានដឹកនាំទេ ពីព្រោះកម្លាំងដែលយើងចេញចល័តចេះទៅ គេឲ្យយើងហ្នឹងនៅនោះឯង ដល់ឲ្យនៅ គេឲ្យយើងធ្វើប្រធានកង ប្រធានក្រុមអីទេ ដល់យូរៗទៅ បានគេឲ្យយើងធ្វើជាប្រធានកងធំអីទៅ ដោយយើងធ្វើការដូចថា ធ្វើការសកម្មទៅដូចថា

ប្រុញៈ ឲ្យរីកចំរើន

សាវីនៈ ហ្នឹងហើយ ។

ប៊ុនថនៈ អីចឹង និយាយថា មាក្រុមហ្នឹងមានកំណត់ឲ្យធ្វើការប៉ុន្មានៗដែរទេ អ្នកមីងក្នុងមួយថ្ងៃ?

សាវីនៈ មួយថ្ងៃហ្នឹងលើកទំនប់ ២ម៉ែត្រគីប ក្នុងមួយនាក់ ក្នុង១នាក់ហ្នឹង ២ម៉ែត្រគីប ។

ប៊ុនថនៈ ទាំងស្រីទាំងប្រុស?

សាវីនៈ ទាំងស្រីទាំងប្រុស ។

ប៊ុនថនៈ ដូចគ្នា?

សាវីនៈ ដូចគ្នា

ប៊ុនថនៈ ចុះកុមារអីមានទេអ្នកមីង?

សាវីនៈ មានខ្លះដែរកុមារ កុមាមានតាមកងកុមាផ្សេង កុមាហ្នឹងលើកដែរ ។

ប៊ុនថនៈ កុមារហ្នឹងគេកំណត់ប៉ុន្មានដែរមីង?

សាវីនៈ មិនដឹងប៉ុន្មានមិនដឹងជា១ម៉ែត្រ ១ម៉ែត្រកន្លះអីទេ អត់ដឹងទេ ។ មាន២-៣នោះ បើថាកន្លែងចល័តពិសេស គេហៅកន្លែងពិសេស អានោះ៣ម៉ែត្រគីប ។ ខ្ញុំនេះ ពួកខ្ញុំនេះធម្មតាទេ លើក២ម៉ែត្រគីប ។

ប៊ុនថន: ២ម៉ែត្រគីប?

សាវីនៈ ហ្នឹងហើយ ។ ១ថ្ងៃ២ម៉ែត្រគីប លើកមិនបានទេអូនអើយ ។ មានតែកាលនោះទៅ លួចខ្លះទៅណាស់ ឧទាហរណ៍ថាថ្ងៃនេះបាន១ម៉ែត្រកន្លះ យើងដាក់វាស់បង្គ្រប់គ្រប់ ថាបាន ២ម៉ែត្រទៅ ។ ខ្លះគេមកចុះតាមនេះយើងដូចយើងធ្វើការរាល់ថ្ងៃហ្នឹង ចុះស៊ីសំណូក សុកប៉ាន់អីខ្លះហើយ ចុះយើងធ្វើការមិននេះណា ។

ប្រុញៈ អ៊ីចឹងអ្នកមីងដឹកនាំក្រុមផងធ្វើការខ្លួនឯងផង?

សាវីនៈ ធ្វើការខ្លួនឯងហ្នឹងផង ។

ប៊ុនថនៈ អ៊ីចឹងអ្នកមីងដូចថាវាស់ដីអីឲ្យ វែកហ្នឹង យើងប្រធានកងហ្នឹង វាស់ខ្លួនឯង ឬមានគេផ្សេង?

សាវីនៈ យើងវាស់ឲ្យគេរួច យើងមើលខ្លួនយើង យើងធ្វើខ្លួនយើងដូចថាយើងដាក់ឲ្យធ្វើ១ ប្រឡោះ២ម៉ែត្រទៅ អាអូនឯង២ម៉ែត្រ មីង២ម៉ែត្រទៅ រៀងគ្នាទៅ អាប្រឡោះអាប្រឡាយ ដឹកធ្វើទំនប់នៅកំបោរស្រែសហ្នឹងឯង ។ ខ្ញុំ២ម៉ែត្រទៅ ២ម៉ែត្រៗ រៀងរហូតទៅ ទាល់តែដល់២-៣គន្លាក់ៗហ្នឹងលើកទំនប់ហ្នឹងណាស់ នៅ ៣គន្លាក់ ។

ប៊ុនថនៈ អ៊ីចឹងវាស់ខ្លួនឯងតែម្ដងអត់មានអ្នកផ្សេងអីវាស់ឲ្យទេ?

សាវីនៈ វាស់ខ្លួនឯង ដូចថាយើងប្រធានកងធំយើងវាស់ខ្លួនឯងហ្នឹង យើងធ្វើខ្លួនឯងទៅ ។

ប៊ុនថនៈ អ្នកមីង២ម៉ែត្រអ៊ីចឹង ដូចថាមានធ្វើអត់ហើយទេអ្នកមីង?

សាវីនៈ មាន អត់ហើយទៅ ហើយខ្លះក៏ហើយទៅ ។

ប៊ុនថនៈ អត់ហើយអ៊ីចឹងធ្វើម៉េចទៅមីង?

សាវីនៈ អត់ហើយអ៊ីចឹង អត់ហើយទៅ មិនដឹងធ្វើម៉េច ហើយគេទុកឲ្យជីកថ្ងៃស្អែកទៅ ។ ថ្ងៃនេះជីកអត់ហើយ អ៊ីចឹងគេឲ្យជីកបន្ថែមទៀត ។ ជួនការក្រោកជីកពីយប់ទៅ ជួនកាល ហើយ ហើយជួនការអត់ហើយទៅ វាកម្រណាស់ ។

ប៊ុនថនៈ អ៊ីចឹងបើនៅសល់ហ្នឹង ថ្ងៃស្អែកហ្នឹងគេបន្ថែមឲ្យទៀត?

សាវីនៈ បន្ថែម ។

ប៊ុនថន: ដឹកថែមៗរហូត?

សាវីន: ដឹកថែមរហូត ។

ប៊ុនថន: ដល់ពេលអត់ហើយអីចឹង ដល់ពេលខាងលើគេមកសរុប...?

សាវីន: យើងស្រួតៗទៅ ។

ប៊ុនថន: គេមកធ្វើយ៉ាងម៉េចទៅ?

សាវីន: មានផែនការថាហើយៗរហូតអីចឹងទៅ ។

ប៊ុនថន: ប៉ុន្តែដាក់ស្តែង គេមកហ្នឹងពិនិត្យឲ្យគេហ្នឹង ដាក់ស្តែងធ្វើយ៉ាងម៉េចទៅ?

សាវីន: ទេ! អាហ្នឹងមិនដឹងធ្វើម៉េចទៅ អាហ្នឹងវានៅតាមកងក្រុមយើងហ្នឹង ចេះតែលួចលាក់គ្នាទៅ ។ ប្រធានកងធំហ្នឹងចុះមកហ្នឹងគ្នាយើង ដូចប្រធានកងវីរ គេក្តាប់រួម៣០០នាក់អីចឹង ទៅ ។ គេមកសួររួម ថាក្រុមនេះក្តាប់ប៉ុន្មាន ៣០នាក់នោះបានប៉ុន្មានទៅ យើងរាយ ការណ៍ទៅ ។

ប៊ុនថន: រាយការណ៍ដាក់ស្តែងតែម្តង?

សាវីន: ដាក់ស្តែងហ្នឹង ប្រឡប់ខ្លះទៅ ។

ប៊ុនថន: ហើយកាលហ្នឹងកងវីរៈខាងណាមីងលើមីងទៀត?

សាវីន: ទេ នៅកងវីរៈហ្នឹងមានអ្នកផ្សេងទៀត ។

ប៊ុនថន: បាទ! ពីណាគេមីងមានចាំឈ្មោះទេកាលហ្នឹង?

សាវីន: មិនចាំទេ មិនដឹងទៅនៅឯណា ។

ប្រុញ: ប្រធានកងវីរៈណាស់?

សាវីន: ហ្នឹងហើយប្រធានកងវីរៈនោះ ។

ប៊ុនថន: គាត់ហ្នឹងអ្នកស្រុកណាដែលអ្នកមីង?

សាវីន: គាត់ហ្នឹងអ្នកស្រុកឯងដែលហ្នឹង ខ្ញុំភ្លេចឈ្មោះទៅ ។

ប៊ុនថន: អ្នកខាងព្រះនេតព្រះនេះដែរ?

សាវីន: អ្នកខាងព្រះនេតព្រះនេះដែរហ្នឹងណាស់ ។ ប្រធានវីរៈ ចេះតែរើដាក់ទៅពីនេះពីនោះទៅ. ។ ជួនកាលគេចូលយូរទៅគេចាស់ទៅ គេធ្វើគេបានទៅជាកើតជាវីរៈទៅ ។

ប៊ុនថន: តែគាត់នៅរស់ដែលទេអ្នកមីង?

សាវីន: នៅរស់តែមិនដឹងថាទៅនៅឯណាទេ នេះ បែកគ្នាអស់ទៅនេះ ។

ប្រុញៈ សម័យហ្នឹង មានប្រធានកងដែលអ្នកមីងស្គាល់មានច្រើនទេអ្នកមីង?

សារីនៈ ស្គាល់ច្រើនដែលតែភ្លេចអស់ហើយ វាយូរឆ្នាំណាស់ហើយ ។

ប្រុញៈ ប៉ុន្តែ ភាគច្រើនអ្នកនៅភូមិជាមួយនឹងគ្នា ឬម៉េចដែរ?

សារីនៈ អត់ទេ! ភូមិផ្សេងៗ ឆ្ងាយៗពីគ្នា ។ អ្នកភូមិរបស់យើងហ្នឹង ដូចថានៅក្នុងភូមិហ្នឹង ម៉ាភូមិប៉ោយព្រីងដែលទៅនៅ ប្រហែលជា៨-១០នាក់គ្នាឯងហ្នឹង ដែលថានារីយុវជនគ្នាឯងហ្នឹង ។ ដោយសារចល័តគ្រប់តែភូមិហ្នឹងនោះ មិនដឹងថាមកពីណាមកពីណី ។ ហើយមកពីភ្នំពេញក៏ដោយក៏ឲ្យទៅលើកជាមួយនឹងគ្នាដែលនោះ ។

ប៊ុនថនៈ អីចឹងអ្នកភ្នំពេញមកហ្នឹង ដូចថាមកពីភ្នំពេញអីចឹង ដូចថាធ្វើការងារធ្ងន់អីចឹង យ៉ាងម៉េចដែលអ្នកមីង?

សារីនៈ ធ្វើការទៅ ជួនកាលអាខ្លះទៅ វាខំធ្វើទៅវាបានដែលទៅ ។ ជួនកាលទៅ បើដាក់កម្លាំងម្នាក់ៗមិនរួច សុំបន្ថែមមកគេឲ្យដាក់២នាក់ទៅក្នុង២ម៉ែត្រគីបហ្នឹងណាស់ ។ គេអាចបញ្ចូលបាន២ម៉ែត្រគីបទៅ. ធ្វើហើយទៅ វាអីចេសដែលណាស់ ។ ដូចថា គ្នាយើងហ្នឹងយើងចេះតែថា កម្លាំងគ្នាហ្នឹងឈឺធ្វើមិនរួចផងអីចឹង បន្ថែមទៅណាស់ ។

ប៊ុនថនៈ បន្ថែម! អត់មានដកចេញទេ?

សារីនៈ អត់មានទេ ។

ប៊ុនថនៈ អត់មានផ្លាស់ប្តូរទេ.?

សារីនៈ វាមានផ្លាស់ប្តូរខ្លះដែល ។ ហើយដល់ពេលអីចុះទៅ សុំគេបន្ថែមទៅ គេដាក់ឲ្យទៅ ។ ដក់ពីនោះមកបញ្ចូលគ្នាទៅ ។

ប្រុញៈ ធ្វើអត់ហើយហ្នឹងគេពិន័យទេអ្នកមីង.?

សារីនៈ មិនពិន័យទេ សុទ្ធតែលួចលាក់បានគ្នាឯងហ្នឹង ។ ក៏អីចឹងពីព្រោះធ្វើៗទៅចេះតែស្គាល់គ្នា ទៅ ។ ឆិនឆែគ្នាទៅណាស់ បើតាមតែធ្វើហ្នឹងនោះធ្វើម្តេចបានធ្វើរួច២ម៉ែត្រគីបនោះ ណាស់ ។ ធម្មតាទេណាស់ ទទឹង២ម៉ែត្របណ្តោយ២ម៉ែត្រណាស់ ជម្រៅកន្លះម៉ែត្រ ។ បើសិនណា ជា១ម៉ែត្រគីបធម្មតាជម្រៅ១ម៉ែត្រទទឹង១ម៉ែត្រ ។

ប៊ុនថនៈ ១ម៉ែត្រការេ ។

សារីនៈ ហ្នឹងហើយ ។ ១ម៉ែត្រការេទទឹងមួយម៉ែត្រ ។

ប៊ុនថនៈ ហ្នឹងហើយ ។

សាវីនៈ ដល់អានេះយើងយកជម្រៅកន្លះម៉ែត្រ បណ្ដោយ២ទទឹង២ ២ម៉ែត្រការេ ។

ប៊ុនថនៈ អ្នកមីងដូចមិញថាផ្លាស់ប្ដូរហ្នឹង កាលហ្នឹងគេដកទៅណាវិញ?

សាវីនៈ ដកដាក់ធ្វើជាមួយនឹងគ្នា មានដូរទៅណាហ្នឹងឯង ។ ដល់ពីកន្លែងក្រុមឈឺអត់បានធ្វើហ្នឹងណាស់ ។ ទៅក៏សល់ទៅយើងដកមកជួយកម្លាំងគ្នាខ្លះទៅណាស់ ។

ប៊ុនថនៈ អត់មានដកចេញចេញទេ?

សាវីនៈ អត់ទេ! អត់មានដកចេញទេ ។ គេធ្វើជាមួយនឹងគ្នាហ្នឹងឯង ។

ប៊ុនថនៈ ចុះមានអ្នកឈឺដែលអ្នកមីង?

សាវីនៈ មាន! មិនអត់ទេ អ្នកឈឺមាន ។ ក្នុង១ថ្ងៃៗឈឺ៤-១០នាក់ដែលហ្នឹងណាស់ មិនមានអត់ទេ ។

ប៊ុនថនៈ ឈឺភាគច្រើនឈឺអីវិញអ្នកមីង?

សាវីនៈ ឈឺហ្នឹងមានអី ។ មានតែឈឺគ្រុន រាគមូល រាគអាចម៍ អីហ្នឹង ។ មិនមានជំងឺអីទេ មានតែជំងឺប៉ុណ្ណោះឯង ។ ជំងឺគ្រុន ជំងឺរាគ ជំងឺចុះនោះឯង ។

ប៊ុនថនៈ ដល់ពេលអ្នកឈឺគេព្យាបាលនៅហ្នឹងតែម្ដង ឬមួយគេបញ្ជូនទៅណាទៀត?

សាវីនៈ គេឲ្យដេកនៅកន្លែងហ្នឹងតែម្ដង ។

ប៊ុនថនៈ ដេកកន្លែងហ្នឹង ។

សាវីនៈ ដេកឈឺខ្លាំងបានគេបញ្ជូនទៅ ណាទេ ។ គេបញ្ជូនទៅហ្នឹងមិនដឹងយកទៅណាទេ. ។

ប៊ុនថនៈ ចុះមីងអត់ដែលឈឺទេអ្នកមីង?

សាវីនៈ ឈឺខ្លះដែលហ្នឹងណាស់ ។ ឈឺគ្រុនអីហ្នឹងទៅ គេឲ្យថ្នាំអីដែរហ្នឹងណាស់ គេឲ្យលេបទៅជាទៅ ។

ប៊ុនថនៈ ហើយចុះមីងនៅនោះរបបអីគេគិតម៉េចដែលមីង?

សាវីនៈ របបហ្នឹងគេឲ្យស៊ី កាលហ្នឹង ១ថ្ងៃ១កំប៉ុងអីទេ ។ គេឲ្យស៊ីហ្នឹង ។

ប៊ុនថនៈ ក្នុង១នាក់?

សាវីនៈ ក្នុង១នាក់ ។ ១ថ្ងៃ១កំប៉ុងអីចេសហើយ ។

ប៊ុនថនៈ ១ថ្ងៃ១កំប៉ុង ។

សាវីនៈ ជួនកាលឆ្អែតទៅ ហើយជួនកាលអត់ឆ្អែតទៅដែលហ្នឹងណាស់ ។ ស៊ីហ្នឹងអត់បានគ្រប់គ្រាន់ទេ តែចល័តហ្នឹង វាគ្រាន់បែជាងនៅភូមិ នៅតាមភូមិហ្នឹងដឹងថាទឹករាវកក្កុកហើយ ។

ប្រុញៈ បបរអ្នកមីង?

សាវីនៈ ហ្នឹងហើយ ។

ប៊ុនថនៈ អត់សូវបានរបបច្រើនទេ? ចាញ់ចល័តទេ?

សាវីនៈ ចាញ់ចល័ត ទេមិនសូវគ្រប់គ្រាប់ប៉ុន្មានទេ វាខ្វះខាតដែលហ្នឹង ។

ប្រុញៈ អ្នកមីងហេតុអ្វីបានជាគេហៅកងពិសេសអ្នកមីង? កងពិសេស?

សាវីនៈ កងពិសេសហ្នឹង គេធ្វើលឿនៗ ១ថ្ងៃ៣ម៉ែត្រគីបហ្នឹងគេហើយ ។

ប្រុញៈ ហើយពួកហ្នឹង ខុសពីយើងធម្មតាម៉េចដែរ?

សាវីនៈ ខុសពីយើងធម្មតា តែមនុស្សយើងធម្មតាដែលហ្នឹង ។ តែគ្រាន់តែគេហ្នឹង កំលាំងមនុស្សប្រុស នារីយុវជន ប៉ុន្តែគេធ្វើការប្រណាំងប្រជែងគ្នាណាស់ ។ គេធ្វើការយកស្នាដៃណាស់ ។ គេខំធ្វើទៅ១ថ្ងៃ៣ម៉ែត្រគីបហ្នឹង គេហើយតាំងពីម៉ោង២ ម៉ោង៣ ។

ប្រុញៈ ក្នុងកងពិសេសហ្នឹង ឧទាហរណ៍ថាក្នុងការដ្ឋានហ្នឹង នៅកំបោស្រែសហ្នឹងមានកងពិសេសហ្នឹងប៉ុន្មានដែលទៅអ្នកមីង?

សាវីនៈ មិនដឹងដែលហ្នឹង ។ ប៉ុន្មានកងប៉ុន្មានក្រុមអីហ្នឹង ដូចថាអត់ដែលដឹងទេ ។ កងក្រុមរបស់ពួកខ្ញុំហ្នឹង ឲ្យដឹងតែ១វីរទៅ តាមហ្នឹង ។ អត់មានដឹងក្រុមគេផ្សេងទេ អត់មានរវល់រវាក់ជាមួយនឹងគ្នាទេ ។

ដូចតែពេលដែលយើងហ្នឹងប្រជុំហ្នឹងបានគេហៅយើងទៅប្រជុំទាំងអស់ គ្នា ។ ដូចថាប្រជុំហ្នឹង១អាទិត្យឡើងទៅប្រជុំម្តង មួយខែឡើងទៅម្តង ។ ប្រជុំហ្នឹងមិនមែនប្រជុំទៅឆ្ងាយទេ ប្រជុំហ្នឹង នៅជិតៗហ្នឹងនោះឯង ។ ម៉ាកងៗហៅប្រជុំនៅ ឯងទៅ ។

ប៊ុនថនៈ ដូចថាមីង កងរបស់មីងក្តាប់ហ្នឹង មីងហៅម៉ាកងទៅប្រជុំទៅ.?

សាវីនៈ អត់ទេ ដូចថាគេហៅតាមប្រធានកង ។ ប្រធានកងតូចប្រធានកងធំ ឬក៏ប្រធានក្រុមហ្នឹងគេហៅប្រជុំ គេធ្វើការពិភាក្សាគ្នាហ្នឹងម៉េចៗហ្នឹងណាស់ ។

ប៊ុនថនៈ កាលហ្នឹងពីណាអ្នកមកកាលហ្នឹង?

សាវីនៈ មានពីណា! គ្នាយើងពួកកងវីរៈហ្នឹងណាស់ ។ ដល់ពេលយូរទៅបានតាវ៉ាល់អី គាត់ចុះមកម្តង ។

ប៊ុនថនៈ រយៈពេលប៉ុន្មានអាទិត្យប៉ុន្មានខែបានគាត់ហ្នឹងចុះមកម្តងហ្នឹង?

សាវីនៈ មិនដឹងប៉ុន្មានខែប៉ុន្មានថ្ងៃទេ មិនសូវដែលដឹងទេ មិនសូវឃើញគាត់ហ្នឹងដែលហ្នឹង ។ តាវ៉ាល់យូរៗឃើញម្ដង ម៉ាចល័តអីហ្នឹងឃើញគាត់ម្ដង មិនសូវដែលស្គាល់គាត់ផងហ្នឹង ។

ប៊ុនថនៈ ប៉ុន្តែមកហ្នឹង គាត់និយាយពីអីមីង? ពេលមកប្រជុំហ្នឹង?

សាវីនៈ ពីរឿងធ្វើការងារហ្នឹង ។ មាននិយាយពីរឿងអី យើងខំធ្វើការងារ អ្នកណាមិនធ្វើការងារមិនខំពលកម្មធ្វើការទំនុកស្រុកអីហ្នឹង ។ សម័យនោះ គេចេះតែថាហើយ ថាម៉េចចេះតែថាពីយើងទៅ ឲ្យយើងហ្នឹងខំធ្វើការមិនធ្វើការ ។ គេប្រមាថមើលងាយយើងហ្នឹងក៏ថាបានដែល ។

ប្រុញៈ អាចដល់សម្លាប់យើងទេអ្នកមីង?

សាវីនៈ សម្លាប់មានដែលហ្នឹង ។

ប្រុញៈ គេមាននិយាយគំរាមទេ?

សាវីនៈ គំរាម! អ្នកណាមិនធ្វើការ ប្រយ័ត្នអង្គការយកទៅសម្លាប់ចោលស្អីៗហ្នឹងណាស់ ។

ប៊ុនថនៈ អីចឹង កាលពីនិយាយ ក្រៅពីគាត់ហ្នឹង មានពីណាផ្សេងមកជាមួយគាត់អីទេ? ដូចថាអ្នកដឹកនាំមកជាមួយនឹងតាវ៉ាល់អីហ្នឹង? មានទេ.?

សាវីនៈ មានពួកនិរសា របស់គាត់ហ្នឹងហើយ ។

ប៊ុនថនៈ មីងមានចាំឈ្មោះទេមីង?

សាវីនៈ ទេមិនស្គាល់ទេ មិនដែលស្គាល់ទេ ។

ប៊ុនថនៈ ចុះ តាម៉ោង អីនោះ?

សាវីនៈ តាម៉ោងឃើញ ។ ក៏ដូចថាពេលគេហៅទៅរៀននៅស្វាយ ។

ប៊ុនថនៈ អូ! មីងបានរៀនដល់ហ្នឹងដែល?

សាវីនៈ បានឡើងទៅរៀន១ដងឬ២ដងទេ ។ ទៅទួលស្វាយហ្នឹង អនុប្រធានកងធំ ប្រធានកងធំប្រធានកងតូចហ្នឹង គេឲ្យឡើងទៅរៀន ។ ដូចថាយើងហ្នឹងជប់លៀងណាស់ គេឲ្យយើងហ្នឹងធ្វើចប់ ដូចការងារហ្នឹង ឲ្យយើងឡើងទៅ ទៅរៀនសូត្រ គេហៅយើង ជប់លៀង ។ កាលហ្នឹងនៅស្វាយហ្នឹងមិនដឹង ត្រង់ណាទេ អត់ស្គាល់ទេ ។ ចាំអត់បានទៀតចាំអត់បានទៀត ។ បានថាគេហៅឡើងទៅហ្នឹង ងាប់បាត់ទៅហើយ ។

ប៊ុនថនៈ ច្រើនគ្នាទេ អ្នកមីងទៅហ្នឹង?

សាវីនៈ ច្រើនគ្នាតើ រាប់រយនាក់ណាស់ ។ ទៅហ្នឹង១០០នាក់ជាងទេដឹង ។

ប៊ុនថន:	បាទ!

ប្រុញ:	ទៅសុទ្ធតែប្រធានកងធំអ្នកមីង?

សាវីន:	ប្រធានកងធំ ប្រធានកងតូច ប្រធានវីរៈអីហ្នឹងទៅហើយ ឡើងទៅហើយ ។

ប៊ុនថន:	ក្នុងតំបន់៥ហ្នឹង?

សាវីន:	ហ្នឹងហើយ ។ ឡើងទៅប្រជុំនៅខេត្តហ្នឹង នៅស្វាយ ។

ប្រុញ:	កាលហ្នឹងពីណាគេ អ្នកមកបង្រៀន?

សាវីន:	តាវ៉ាល់ ។

ប្រុញ:	តាវ៉ាល់?

សាវីន:	អត់ទេ តាមេង ធំជាងតាវ៉ាល់ ។

ប្រុញ:	តាមង ធំជាង ។

សាវីន:	តាវ៉ាល់ គ្រាន់តែប្រធានកងចល័តទេ តាវ៉ាល់ហ្នឹងនោះ ។ បើតាមងនេះ ប្រធានតំបន់ដូចយើងខេត្តបន្ទាយមានជ័យហ្នឹង ប្រធានខេត្តហ្នឹងណាស់ ។

ប៊ុនថន:	អីចឹង តាមងហ្នឹងធំជាងតាវ៉ាល់?

សាវីន:	តាមងហ្នឹងធំជាងតាវ៉ាល់? ។

ប៊ុនថន:	អីចឹងក្រៅពីតាមង តាវ៉ាល់ហ្នឹង មានអ្នកណាផ្សេងទៀតទេអ្នកមីង?

សាវីន:	ទេ! មិនដឹងអ្នកណាទៀតទេ មិនដែលស្គាល់ទេ ។

ប៊ុនថន:	អីចឹងទៅបន្ទាយមានជ័យហ្នឹងទៅប៉ុន្មានថ្ងៃអ្នកមីង? ទៅសេរីសោភ័ណ្ឌនេះ?

សាវីន:	កាលនោះទៅ២-៣ថ្ងៃដែល គេឲ្យមកវិញហ្នឹងតាមកងណាយើងវិញទៅ ។

ប៊ុនថន:	គេដឹកឡានទៅឬក៏?

សាវីន:	គេដឹកឡានទៅ ។

ប៊ុនថន:	កាលហ្នឹង គេទៅប្រជុំ?

សាវីន:	ទៅប្រជុំ ។

ប៊ុនថន:	ទៅជប់លៀង ទៅ?

សាវីន:	គេហៅទៅប្រជុំ ។

ប្រុញ:	ពេលប្រជុំហ្នឹងគេនិយាយថាម៉េចដែលមីង ។

សាវីន:	ទៅប្រជុំហ្នឹងគេនិយាយពីរឿងការងារហ្នឹងហើយ ។

ប្រុញៈ គេអត់មានហេតុផលផ្សេងអីទេ.។ គេអត់មានប្រាប់ថាហេតុផលម៉េចៗទេឡូតែ យើងធ្វើការងារទៅដើម្បីឲ្យអង្គការស្អីៗទៅណាស់។ គេចេះតែនិយាយទៅ។

សាវីនៈ កាលហ្នឹងពីណាអ្នកមកប្រជុំជាមួយនឹង?

សាវីនៈ កាលហ្នឹង តាវ៉ាន់ អេ តាម៉ានគេមកប្រជុំហ្នឹង។

ប៊ុនថនៈ មានអ្នកផ្សេងទៀតទេ?

សាវីនៈ មានដែល តែយើងហ្នឹងអត់ស្គាល់។ ស្គាល់តែតាម៉ានមួយហ្នឹង អ្នកមកពីណាពីនីអី ខ្ញុំអត់ស្គាល់ទេ។

ប៊ុនថនៈ កាលហ្នឹងមកនៅម្តុំណាមីង?

សាវីនៈ ទេចាំអត់បានទេ។ អត់ដែលស្គាល់ច្បាស់ទេ ដូចស្វាយរបស់ខ្ញុំពីដើមហ្នឹងនៅតូចៗស្វាយហ្នឹងមិនសូវដែលស្គាល់ទេ។

ប្រុញៈ ក្នុងពេលហ្នឹង ក្នុងពេលដែលធ្វើការនៅស្រែកំបោរហ្នឹងអ្នកមីង? អូ! កំបោរស្រេសហ្នឹងអេស?

សាវីនៈ ហ្នឹងហើយ។ ក្រោយពីកំបោរស្រេសហើយក៏ទៅចល័តពេញតែណា ពេញតែនីនោះដល់ពេលទៅភ្នំហ្នឹង ទៅភ្នំខ្នាលកូន ភ្នំបាក់អីហ្នឹង ដើរនៅតាមត្រពីសត្រពាសទៅណាស់គេលើកទំនប់នេះរួច ចប់ពីទំនប់នេះទៅទំនប់នោះ។

ប៊ុនថនៈ ទំនប់ណាមីងវិញ?

សាវីនៈ ទំនប់ត្រពាំងថ្មហ្នឹងហើយ បានតែពីត្រពាំងថ្ម បានរួចពីត្រពាំងថ្មហើយ បានគេដកយើងចល័តធ្វើចំការកប្បាសអីនោះ នៅភ្នំបាក់ ភ្នំចំការខ្នុរនោះឯង។

ប៊ុនថនៈ អីចឹង មីង ពីកំបោស្រេសហើយទៅត្រពាំងថ្មតែម្តង?

សាវីនៈ ហ្នឹងហើយទៅ ត្រពាំងថ្ម។

ប៊ុនថនៈ អីចឹងកម្លាំងរបស់មីងហ្នឹងទៅទាំងអស់មីង?

សាវីនៈ ទៅបែកខ្ញែកគ្នាទៅ បែកបក្សពួកគ្នាទៅ ខ្ញុំក៏មិនសូវបាននៅជាប់លាប់គ្នាដែរ។ ហើយដល់ ពេលទៅបែកទៅលើកទំនប់កំបោស្រេសយើងនេះចប់ ហើយដល់ចប់ហើយបានបញ្ជូន យើងទៅខាងនោះទៀត។ អាកំបោស្រេសហ្នឹង បានគេជប់លៀងចាស់ៗដែលនៅក្នុង ភូមិនេះយកទៅដាំបាយដាំស្លអីហ្នឹងឲ្យជប់លៀងនារីយុវជនដែលនៅទំនប់ហ្នឹងណាស់។ គេលេងសិល្បៈយើងមើលដែរ។

ប៊ុនថនៈ គេលេងសិល្បៈដែរ?

សាវីនៈ	គេលេងសិល្បៈអីហ្នឹងឲ្យមើល។ កាលហ្នឹង ឆោម ឆវិនហ្នឹងហើយគេអ្នកច្រៀងនោះ។ អូ! អ្នកស្អីម៉េចទេ។ បើមិនឆោម ឆវិន អាណាគេទេ កាលហ្នឹងភ្លេចដែលហើយឈ្មោះអីទេ។

ប្រុញៈ	គេនិយាយពីអីគេដែល សិល្បៈហ្នឹងអ្នកមីង?

សាវីនៈ	សិល្បៈហ្នឹងគេរាំច្រៀងហ្នឹងណាស់ សម័យនោះគេលែកទំនប់ជីកប្រឡាយហ្នឹង តែប៉ុណ្ណោះឯង។

ប្រុញៈ	អូ! សិល្បៈគេលែងរបៀបអ្នកស្ទូងអីហ្នឹង?

សាវីនៈ	ហ្នឹងហើយ អ្នកស្ទូង អ្នកដក អ្នកកាប់ អ្នកនោះអីដូចគ្នាហ្នឹងហើយអ្នកនោះឯង។

ប៊ុនថនៈ	មីងថា ឆោម ឆវិនសព្វថ្ងៃហ្នឹង អ្នកចម្រៀងហ្នឹងមីង?

សាវីនៈ	អ្នកចម្រៀងហ្នឹងហើយ ចុះគេសម័យពល់ ពត ឆោមឆវិន។

ប៊ុនថនៈ	អូ! ច្រៀងនៅសម័យ ពល់ ពត ដែលសម័យហ្នឹង?

សាវីនៈ	ហ្នឹងហើយ។

ប៊ុនថនៈ	ចុះក្រៅពីគាត់ហ្នឹងមានអ្នកណាផ្សេងទេអ្នកមីង? អ្នកចម្រៀងដែលស្គាល់?

សាវីនៈ	អត់ទេ! ចាំបានតែប៉ុណ្ណោះឯង។

ប៊ុនថនៈ	អីចឹង៣ថ្ងៃតែម្តង? ទាំងយប់ទាំងថ្ងៃ?

សាវីនៈ	ទេ ថ្ងៃឡើងក៏សំរាកទៅ លេងតែយប់ទេ លេងតែពេលយប់។ កាលហ្នឹង ខែជិតចូលឆ្នាំ។ ចប់ទំនប់នេះចូលឆ្នាំ ដល់ពេលចូលឆ្នាំទៅ គេឲ្យសំរាក៣ថ្ងៃទៅ។

ប៊ុនថនៈ	ធ្វើអីខ្លះម្ហូបអី?

សាវីនៈ	ម្ហូបនេះមានអី។

ប្រុញៈ	អ្នកមីងសុំសួរកំបោស្រេស? កាលហ្នឹង កំបោស្រេសហ្នឹងមានមនុស្សធ្វើច្រើនទេអ្នកមីង?

សាវីនៈ	ធ្វើច្រើន។

ប្រុញៈ	ប្រហែលជាប៉ុន្មានដែលទៅអ្នកមីង? ប្រហែលជាប៉ុន្មានម៉ឺននាក់ទៅអ្នកមីង?

សាវីនៈ	អូ! ច្រើនណាស់ ប្រហែលរាប់ពាន់នាក់។

ប្រុញៈ	អីចឹងមីង មីងធ្វើអីចឹងដល់ពេលហូបអីហ្នឹងគ្រប់គ្រាន់ទេធ្វើអីចឹង?

សាវីនៈ	ពេលដែលយើងចល័តអីចឹងយើងហូបគ្រប់គ្រាន់ដែរ។

ប្រុញៈ	អ្នកធ្វើការអីចឹង។ ហូបគ្រប់គ្រាន់?

សាវីនៈ ហ្នឹងហើយ ហូបគ្រប់គ្រាន់ ។

ប្រុញៈ ចុះមានទឹកអីហ្នឹងប្រែគ្រប់គ្រាន់ទេ អ្នកមីង?

សាវីនៈ ទឹកអីហ្នឹង គេឲ្យទឹកអីហ្នឹង យកមកដឹកអីហ្នឹង ទឹកជិតៗទៅ ។

ប្រុញៈ គេដឹកយកមកឲ្យយើងហ្នឹងហូបអេស?

សាវីនៈ ហ្នឹងហើយយកមកឲ្យយើងហ្នឹងហូបទៅ ។ អីចឹងពីដើមមិនទាន់មានដាំទឹកហូបអី ទឹកកន្លក់ ។

ប្រុញៈ នៅហ្នឹងអត់មានទឹកប្រែ? អីល្អអាចហូបបានទេមិញហ្នឹង?

សាវីនៈ មានដែលជិតៗហ្នឹង នៅត្រពាំងបឹងបួ មានដែលពីដើមមិញហ្នឹងនោះ ។ វាមិនអត់ទេ អាយើងទឹកដឹកនោះណាស់ ។

ប្រុញៈ គេចែកឲ្យហូបប្តូមួយយ៉ាងម៉េចមីង?

សាវីនៈ អត់ទេ ។ បើបាយគេឲ្យស៊ីមួយវែ្លតដែល យើងចល័តធ្វើការហ្នឹងណាស់ ដូចថា១កងហ្នឹង គេឲ្យយើងហ្នឹងដាំទៅណាស់ ១កងធំហ្នឹង ឲ្យយើងដាំបាយហូប១នាក់២នាក់ទៅ ។ ហើយទៅឲ្យយើងដាំបាយហូបទៅណាស់ តែម្ហូបហ្នឹង អត់មានអីទេ មានតែប្រហុក ហ្នឹងឯង ។ ស្ងោទឹកប្រហុកហ្នឹងឯង ។

ប្រុញៈ ១កងធំហ្នឹង គេឲ្យយើងប៉ុន្មានកំប៉ុងហូបដែលកាលហ្នឹង?

សាវីនៈ ទេ! គេឲ្យហូបមួយវែ្លតដែលហ្នឹង យើងចល័តហ្នឹងដាំខ្លួនយើង គេក៏ឲ្យអ្នកដាំបាយទៅ ។

ប្រុញៈ ទៅធ្វើការធ្ងន់ហ្នឹងគេឲ្យហូបវែ្លត ។

សាវីនៈ គេឲ្យហូបវែ្លត ។

ប្រុញៈ ប៉ុន្តែទឹកគេឲ្យដឹកមកហូប?

សាវីនៈ គេឲ្យយើងហ្នឹងប្រើដឹកទៅមានត្រពាំងអីហ្នឹង នៅជិតទៅយើងដងតាមត្រពាំងអីហ្នឹង បឹងអីទៅ ។

ប្រុញៈ ចុះយើងគេឲ្យទៅដងដែល ពេលយើងធ្វើការអីហ្នឹង?

សាវីនៈ គេឲ្យទៅដងតើ ។ គេឲ្យទៅដង ។

ប្រុញៈ ពេលដែលនៅហ្នឹង ជំងឺមានច្រើនទេអ្នកមីង?

សាវីនៈ ជំងឺមានច្រើនណាស់ នៅហ្នឹង ។ ខែប្រាំងអីទៅ ជំងឺរាគមួល ស្លីហ្នឹងច្រើនណាស់ ។

ប្រុញៈ ស្លាប់ច្រើនទេអ្នកមីង កាលមានប្រជាជនធ្វើការនៅហ្នឹងនោះ?

សាវីនៈ អត់សូវដឹងទេ ដល់ពេលអីចឹង អត់សូវដឹងទេ ។ ជំងឺនោះ ឈឺខ្លាំងបានគេបញ្ជូនទៅ ។

ប្រុញៈ បញ្ជូនទៅហ្នឹង បញ្ជូនទៅពេទ្យណាវិញ?

សាវីនៈ មិនដឹង មិនដឹងនៅពេទ្យនៅណាទេ មិនដឹងថាពេទ្យនៅរហាត់ នៅណាទេ មិនដឹងថា ពេទ្យរបស់គេនៅឯណាទេ ។ គេអ្នកជំងឺធ្ងន់ៗហ្នឹង បានគេដឹកយកទៅ ។ យើងធម្មតាគ្រុនអីហ្នឹង គេចែកថ្នាំឲ្យទៅ ។

ប្រុញៈ ដល់ពេលសម្រាកគេឲ្យសម្រាកនៅកន្លែងណាទៅ?

សាវីនៈ សម្រាកនៅកន្លែងធ្វើការ ។

ប្រុញៈ គេធ្វើរោង?

សាវីនៈ គេធ្វើរោងហ្នឹង ដេកផ្ទាល់ហ្នឹងដី ។

ប្រុញៈ ដេកផ្ទាល់ដី?

សាវីនៈ ហ្នឹងហើយ ។

ប្រុញៈ មានកន្ទេលអីទេ?

សាវីនៈ កន្ទេលយើងយកពីភ្នំមូងភ្លយយើងយកពីផ្ទះទៅ ។

ប្រុញៈ អីចឹងអ្នកណាអត់ទៅ?

សាវីនៈ អ្នកណាអត់ទៅ យើងហៅគ្នាចូលគេងជាមួយហ្នឹងទៅណាស់ ។ បើអ្នកណាមានក៏ហីទេ បើអ្នកណាមិនមានចូលជាមួយនឹងគ្នាទៅ ។

ប្រុញៈ ចុះអង្គការគេអត់ដោះស្រាយឲ្យខ្លះទេ?

សាវីនៈ គេដោះស្រាយឲ្យខ្លះដែរ តែដោះស្រាយវាមិនបានគ្រប់គ្រាន់ទេកាលហ្នឹង ណាស់ ។ ដូចថាខ្វះខាតអីចឹង ឲ្យមួយក្រុមមួយកងទៅណា ខ្វះទៅ គេឲ្យ១-២ទៅ ដែលឲ្យគ្រប់ទេណាស់ ។ ដូចថាយើងមានអីចឹងទៅ យើងចេះតែដាក់ទៅតាមខ្លួនទៅ?

ប្រុញៈ នៅហ្នឹង មាន ឧទាហរណ៍កូនក្មេងអីហ្នឹងទៅជាមួយនឹងឪពុកម្តាយដែលទេមីង?

សាវីនៈ អត់មានសោះ ។

ប្រុញៈ អត់មានសោះ ។ អីចឹងកូនរបស់គាត់ហ្នឹង នៅក្មេងៗ អីចឹងធ្វើម៉េចទៅ?

សាវីនៈ អត់ទៅក្មេងនៅតាមភូមិអត់មានទៅវិលនៅកន្លែងនោះទេ ។

ប្រុញៈ ទោះបីគាត់ហ្នឹងកូនខ្ចីអីក៏ដោយ ក៏យកគាត់ទៅធ្វើនៅហ្នឹងដែលឬម៉េចដែល?

សាវីនៈ ទេ! អត់មានទេ ដែលពេលដែលខ្ញុំមកធ្វើទំនប់ហ្នឹង អត់មានកូនខ្ចី អីទេ មានតែនារី និងយុវជន ដែលទៅជីកទំនប់ហ្នឹង មានតែនារី យុវជន ។

ប្រុញៈ អត់មានប្តីប្រពន្ធអីហ្នឹង អត់ទៅដែលឬមួយយ៉ាងម៉េចដែរមីង?

សារីនៈ អត់មានទៅដែល ទៅតែនារីយុវជនសុទ្ធសាធ ហើយនឹងកុមារក្មេងៗតូចៗណាស់ កុមារ ១៣-១៨ឆ្នាំទៅ ។

ប្រុញៈ ទៅធ្វើហ្នឹងដែល?

សារីនៈ ហ្នឹងហើយទៅធ្វើ១ម៉ែត្រ ១ម៉ែត្រកន្ទះអីទៅណាស់ៗ កាលហ្នឹង នៅតាមកងផ្សេង យើងមានខ្លះដែលកាលហ្នឹងណាស់ គេហៅកងកុមារកងនារីយុវជនហ្នឹងមានដែល ហ្នឹងហើយមានកងពិសេស កងកុមារ នារីយុវជន វាមានតាមកងហ្នឹងទៅៗ

ប្រុញៈ នៅហ្នឹង មានគេសម្លាប់មនុស្សអីច្រើនទេ កាលហ្នឹង?

សារីនៈ ដល់ពេលអីចឹង ខ្ញុំអត់ដឹងទេ ធ្លាប់ឮគេនិយាយអីហ្នឹង ខ្ញុំអត់ដឹងទេៗ ខ្ញុំអត់ឃើញច្បាស់ ជាក់ស្តែងហ្នឹងៗ

ប្រុញៈ ធ្លាប់ឮគេសម្លាប់ហ្នឹងដោយសារអីដែលទៅកាលហ្នឹងមីង?

សារីនៈ ដោយសារតែយើងហ្នឹងធ្វើខុសៗ ដូចថាធ្វើការហ្នឹង យើងមិនទៅធ្វើខុសអីចឹងទៅ យើង ខ្ជិលទៅហ្នឹងណាស់ តាមដានយើងទៅ សម្លាប់យើងទៅក៏មានៗ

ប្រុញៈ ភាគច្រើនយើងឮអីចឹងទៅភ័យទេមីង?

សារីនៈ ភ័យដែលតើៗ យើងចេះតែខំធ្វើការទៅ កុំឲ្យគេតាមដានយើងហ្នឹង ដូចពួកខ្ញុំហ្នឹងនេះ គេដាក់ថានាយទុនណាស់ អ្នកមានណាស់ៗ

ប្រុញៈ ខាងមីង?

សារីនៈ ហ្នឹងហើយៗ គេដាក់ខ្ញុំហ្នឹងនាយតទុន ថានិយាយទៅ វាវៃញឆ្ងាយណាស់ គេដាក់យើង ហ្នឹងថា ពីសង្គមយើងវាមានជិះជាន់ស្អីៗហ្នឹងណាស់ៗ

ប្រុញៈ ហើយដល់ពេលខាងអីចឹងទៅ គេត្រួតពិនិត្យជិតដល់ណាស់ៗ

សារីនៈ គេតាមដានមើលទៅ ពិនិត្យមើលទៅ វាមិនមែនៗ ចុះខ្ញុំអ្នកស្រែធ្វើស្អីក៏ខ្ញុំហ្នឹងចេះធ្វើ ដល់ពេលធ្វើអីចឹងទៅហ្នឹង គេតាមដានមើលទៅៗ

ប្រុញៈ ហើយដល់ពេលឮអីចឹង ហើយ មានអ្នកដែលកូនៗកងរបស់យើងហ្នឹង បាត់ច្រើនទេ ដោយសារថាខ្លួចមាន អត់សូវធ្វើការអី? មានគេចាប់យកទៅ បើខាងមេកងយើង ដឹង?

សារីនៈ ដឹងៗ ដឹងថាគេចាប់យកទៅ ដូចថា ឈឺហ្នឹង គេយកទៅ គេយកមកវិញទៅ តាមកង ទៅ ដល់ជាទៅ គេយកមកវិញទៅ ដល់ក្រោយមកហ្នឹង មិនបានយកមកវិញហ្នឹង គេយកទៅកន្លែងផ្សេងហ្នឹង អាហ្នឹង យើងមិនដឹងទេៗ

ប្រុញៈ ចុះអាហ្នឹង ដល់ពេលកូនកងឈឺយើងប្រាប់ទៅមេកងវិញ ។

សាវីនៈ ហ្នឹងហើយប្រាប់ទៅ ។

ប្រុញៈ ហើយគាត់ដោះស្រាយឲ្យយើងហ្នឹងភ្លាមៗទេ?

សាវីនៈ ដោះស្រាយ ។

ប្រុញៈ ដោះស្រាយភ្លាមៗ?

សាវីនៈ ហ្នឹងហើយដូចថាយើងហ្នឹងឈឺ កូនកងហ្នឹង ប្រធានកងតូចរាយការណ៍ប្រាប់ប្រធានកងធំ ។ ហើយប្រធានកងធំហើយ ខ្ញុំទៅមើល មើលហ្នឹងឈឺអីទៅហ្នឹង ពេទ្យគេមានមក ពេទ្យគេចល័តហ្នឹងណាស់គេឲ្យមកហ្នឹង គេឲ្យថ្នាំលេបទៅ ជាទៅ ស្អែកឡើងទៅធ្វើការទៀត ទៅធ្វើការវិញកើត ។ ហើយអ្នកឈឺធ្វើការអត់កើតទៅ គេបញ្ជូនទៅនេះទៅនោះផ្សេងទៅ ខ្ញុំអត់ដឹងគេទេ នោះហើយ ។

ប្រុញៈ ថ្នាំអីគេទៅ?

សាវីនៈ ថ្នាំហ្នឹងជួនកាល ថ្នាំល្អដែលឲ្យហ្នឹង ។

ប្រុញៈ ថ្នាំល្អ ហូបបានជាទៅ ។

សាវីនៈ ហូបបានជាទៅ តែជួនកាលអាចន៍ទន្សាយយើងហ្នឹង ។

ប្រុញៈ គេឲ្យថ្នាំហ្នឹង តាមរយៈជំងឺធ្ងន់បានគេឲ្យថ្នាំល្អ ឬ ម៉េចដែរ?

សាវីនៈ ជំងឺធ្ងន់ផងហ្នឹង ស្គាល់គ្នាផងហ្នឹង បានគេឲ្យថ្នាំល្អ ។ ថាឲ្យថ្នាំល្អហ្នឹងទៅ បានគេយល់គេឲ្យទៅ បើមានថ្នាំល្អគេឲ្យថ្នាំល្អទៅកាលហ្នឹង ។ កាលហ្នឹង មនុស្សយើងមិនសូវមានមានឈឺអីកាលហ្នឹង ។

ប៊ុនថនៈ ទាល់តែស្គាល់គ្នាដែលកាលហ្នឹង?

សាវីនៈ ស្គាល់គ្នា ។ វាមានគ្នាមានពួកដែលកាលហ្នឹងនោះ វាមិនអត់ទេ អារឿងធ្វើការពីសម័យណាក៏ដូចសម័យណាដែរ បើមិនមានបក្សពួកហ្នឹងអត់មានទៅកើតទេ ។ កាលខ្ញុំនោះតែហ៊ានទឹកម៉ែទឹកឪមកហ្នឹង ក៏រត់មកផ្ទះមកហ្នឹងនោះឯង ។ នៅចល័តមិនសូវដែលបានយូរទេ តែចល័ត បាត់ហើយ ។ ទំនប់នេះម៉ារួច ហើយទំនប់នោះម៉ារួចដែរ ។ ចុះ៣ឆ្នាំ ៨ខែ ២០ថ្ងៃខ្ញុំនោះ ។ ទេថាអានោះច្បាស់ហើយ ៣ឆ្នាំ ៨ខែ ២១ថ្ងៃនោះច្បាស់ហើយ ។

ប្រុញៈ ពេលធ្វើហ្នឹងមានខាងប្រធានវីរអីហ្នឹងគេមកឈឺមើលទេ?

សាវីនៈ មកតើមកមួយភ្លេតៗហ្នឹងទៅ យើងឈរពិភាក្សានិយាយគ្នាទៅ ពិភាក្សាគ្នាអង្គុយលេង ទៅ ។

ប្រុញៈ បានពិភាក្សាគ្នាអង្គុយលេង ។

សាវីនៈ និយាយគ្នាពីនេះពីនោះនិយាយគ្នាខ្លះទៅ ។

ប្រុញៈ សុទ្ធតែស្គាល់គ្នាដែលអ្នកមីង?

សាវីនៈ សុទ្ធតែស្គាល់គ្នាដែល ។

ប្រុញៈ ក្រោយពីអ្នកមីងធ្វើការនៅហ្នឹងចប់ហើយ អ្នកមីងទៅត្រពាំងថ្ម? ត្រូវទេអ្នកមីង?

សាវីនៈ ទៅត្រពាំងថ្ម ។ កាលទៅត្រពាំងថ្មហ្នឹង បែកកងបែកក្រុមហ្នឹងទៅ ខ្ញុំនៅកងតូចអីទេ កាលហ្នឹង វាក្មេចដែលទៅហើយកាលហ្នឹង មិនសូវបាននៅជាប់លាប់ទេកាលហ្នឹង ។

ប្រុញៈ ទៅត្រពាំងថ្មហ្នឹង ទាល់តែយើងធ្វើនៅកំបោរស្រេសហើយបាន ឲ្យយើងទៅ ឬយ៉ាងម៉េច ដែលអ្នកមីង?

សាវីនៈ ហ្នឹងហើយធ្វើកំបោរស្រេសហើយបានយើងឲ្យទៅ ឲ្យទៅចល័តនៅនោះទៀត ។

ប្រុញៈ ធ្វើនៅចល័តនេះចប់ប្រហែលខែប៉ុន្មានដែលអ្នកមីង? នៅកំបោរស្រេសហ្នឹង នៅឆ្នាំណា ដែល?

សាវីនៈ ដឹងឆ្នាំណាទេ ចាំមិនបានទេ ។

ប្រុញៈ ចុះដល់ពេលទៅត្រពាំងថ្មអ្នកមីង? មានចាំទេ?

សាវីនៈ ត្រពាំងថ្មហ្នឹងក៏អត់ចាំ ។

ប្រុញៈ កាលទៅដំបូងហ្នឹងមានគេធ្វើការនៅហ្នឹងអត់ទេ?

សាវីនៈ មាន! មានគេមកធ្វើមុនហើយ ។ យើងទៅក្រោយ យើងនៅតាមក្រោយទៅ មានអ្នក ធ្វើមុនៗមកហ្នឹងច្រើនដែរ ។

ប្រុញៈ ទៅហ្នឹងខាងកូនកងរបស់យើងហ្នឹងទៅទាំងអស់ឬមួយយ៉ាងម៉េចដែរអ្នកមីង?

សាវីនៈ វាបែកខ្ញែកគ្នាដល់ពេលសម្រាក អីចឹងទៅ វាបែកខ្ញែកគ្នាមិនដឹងអាណា ទៅណា ទៅនៃ ទៅ ហើយប៉ះជួនកាលអត់បានទៅវិញទៅ ។ នៅតាមភូមិអីហ្នឹង បែកគ្នាទៅ ។

ប្រុញៈ គេអត់ឲ្យទៅ ឬមួយគាត់សុំនៅភូមិនៅក្រុមផ្សេងម៉េច?

សាវីនៈ អត់មានទេ អត់មានសុំនៅទេ ។ គេហៅដូចថាកងយើងហ្នឹង ហៅមក ហៅមកហ្នឹង ថាទំនប់យើងនេះចប់ហើយ ឲ្យយើងត្រលប់មកវិញ ។ មកហ្នឹង វាមិនបានអស់គ្នាទេ ។ យើងដល់ពេលអីចឹង មានប៉ុណ្ណាទៅធ្វើការប៉ុណ្ណោះ ទៅខ្លះទៅ មិនដឹងខ្លះ គេបញ្ជូនមក

បណ្ដើរៗខាងក្រោយហ្នឹងណាស់ កងនារីយុវជននៅណាហ្នឹង គេឲ្យបញ្ជូនមកវិញមក នៅឯណាហ្នឹង គេឲ្យបញ្ជូនមកវិញទៅណាស់ ទៅវិញទៅ ។

ប្រុញៈ អ៊ីចឹងកាលក្រុមរបស់អ្នកមីងទៅត្រពាំងថ្មហ្នឹងនៅសល់ប៉ុន្មាននាក់ដែរមីង?

សាវីនៈ មិនដឹងនៅសល់ប៉ុន្មាននាក់ទេ បែកខ្ញែកគ្នាទៅហ្នឹងមិនដឹងនៅសល់ប៉ុន្មាននាក់ទេ ។

ប៊ុនថនៈ អ្នកមីងនៅកងធំដដែល?

សាវីនៈ អត់ទេ! ដល់ពេលចប់ទំនប់នេះទៅ ខ្ញុំអត់បានមានមានកងធំទេ នៅជាកងតូច ពីព្រោះ វាអស់មនុស្សនោះ ពីព្រោះវាអស់គ្នា នៅតែ៣០នាក់ ។ ក្ដាប់៣០នាក់វិញទៅ ។

ប្រុញៈ អ៊ីចឹងអ្នកមីងក្លាយទៅជាប្រធានកងតូចវិញ?

សាវីនៈ ចាស! ប្រធានកងតូចវិញ ។

ប្រុញៈ អ៊ីចឹងពីណាគេប្រធានកងធំវិញ?

សាវីនៈ ទេពីណាប្រធានកងធំអីហ្នឹង អត់ដឹងទេដល់ពេលទៅហ្នឹង ពីព្រោះខ្ញុំទៅហ្នឹងអត់បានយូរដែរ ហ្នឹងទៅហ្នឹងទៅរយៈពេល ប្រមាណទៅគេហៅទៅនេះទៅនោះវិញទៅ ។

ប្រុញៈ ចុះគេអត់ដែលហៅយើងហ្នឹងទៅប្រជុំទេប្រធានកងធំហ្នឹង?

សាវីនៈ ប្រជុំនៅតែហ្នឹងអត់មានដែលប្រជុំទៅណាទេ ប្រជុំនៅកន្លែងនោះឯង ដូចយើងហ្នឹងធ្វើ ការនៅនេះអ៊ីចឹង គេហៅប្រជុំនៅនេះហ្នឹងឯង ។

ប្រុញៈ ពីណាគេ អ្នកមកប្រជុំហ្នឹងមីង?

សាវីនៈ គ្នាឯងហ្នឹង ប្រធានកងធំ ប្រធានកងវីរៈហ្នឹង ប្រជុំ២-៣ថ្ងៃហ្នឹង ថាសឹងតែរាល់ថ្ងៃ ។

ប្រុញៈ សឹងរាល់ថ្ងៃ ។ ហៅប្រធានកងតែម្ដង?

សាវីនៈ គ្រាន់តែហៅមកប្រជុំអីហ្នឹង ប្រជុំរឿងធ្វើការងារអីហ្នឹង ពីណាឈឺអីហ្នឹង គំរាមកំហែង យើងថាអ៊ីចឹងឯងប្រយ័តអង្គការគេមើលមិនឃើញគេយកយើងទៅសម្លាប់អីហ្នឹង គេចេះតែថាអ៊ីចឹងឯង គេឲ្យយើងហ្នឹងខំធ្វើការទៅណាស់ ។ ខ្លាចចេះតែខំហើយ បើមិនអ៊ីចឹងទេ ម៉េចហ្នឹងបានរស់ដល់ប៉ុណ្ណេះទេ ។

ប្រុញៈ អ្នករស់សល់ពីនោះមកសុទ្ធតែ....

សាវីនៈ អូ! វេទនាណាស់ ថាឆ្ងងកាត់ឆ្អែតឆ្អន់ហើយ ។

ប្រុញៈ ហើយកាលមុនហ្នឹងតាវ៉ាល់ហ្នឹង គាត់ទៅគ្រប់គ្រងនៅកន្លែងហ្នឹងវិញដដែលប្ញម៉េច? នៅប្រធាន...?

សារិនៈ នៅប្រធានចល័តរហូត ទៅដល់ត្រពាំងថ្មហ្នឹងទៀតហើយ ក៏នៅតែប្រធានចល័ត រហូតហ្នឹងដែរ ប្រធានចល័តតំបន់ៗ តាវ៉ាល់ហ្នឹង នៅតែគាត់រហូតហ្នឹងឯងៗ

ប្រុញៈ ចុះតាម៉ោងពេលហ្នឹងគាត់នៅដដែល?

សារិនៈ តាមោងគាត់នៅដដែលនៅស្វាយ មិនដឹងគាត់នៅឯណាទេ តែពេលប្រជុំនៅស្វាយៗ

ប្រុញៈ នៅស្វាយៗ តែគាត់ខស្បរាហ៍ចុះមក..?

សារិនៈ ទេអត់ដែលចុះមកទេៗ

ប្រុញៈ តាម៉ោង?

សារិនៈ ហ្នឹងហើយ អត់ដែលចុះមកទេៗ

ប្រុញៈ ហើយនៅត្រពាំងថ្ម ហ្នឹងគេធ្វើការគ្នាច្រើនទេ?

សារិនៈ ច្រើនៗ

ប្រុញៈ ប្រហែលប៉ុន្មានទៅ?

សារិនៈ ប្រហែលរាប់ម៉ឺននាក់ទើដឹងៗ

ប្រុញៈ រាប់ម៉ឺននាក់!

សារិនៈ ធំជាងនេះណាស់ ទំនប់ធំជាងនេះ នៅត្រពាំងថ្មៗ នៅនេះតូចទេ នៅត្រពាំងថ្មបិទអាងៗ

ប្រុញៈ ដឹងថាកន្លែងហ្នឹងហេតុអ្វីបានជាគេទៅធ្វើនៅហ្នឹងទេអ្នកមីង? គេមានប្រាប់ថាហេតុអ្វីបានគេឲ្យធ្វើនៅហ្នឹងទេ?

សារិនៈ ខ្ញុំមិនដឹងទេ គេថាឲ្យយើងហ្នឹងទៅធ្វើទំនប់ជីកប្រឡាយទៅ ហើយក៏ទៅទៅៗ យើងអត់មានបានសួរដេញដោលគេពីរឿងយ៉ាងម៉េចៗ គេឲ្យធ្វើ យើងធ្វើទៅៗ

ប្រុញៈ ពេលប្រជុំអីហ្នឹង គេអត់មានប្រាប់ថា ទប់ហ្នឹងទប់ដើម្បីធ្វើអីទេ?

សារិនៈ ទប់ដើម្បីធ្វើស្រែអីហ្នឹង ទប់ទឹកធ្វើស្រែអីហ្នឹង បង្កបង្កើនផលឲ្យបានច្រើនទេគ្រាន់បានទៅ ហ្នឹង បញ្ជូនទៅអស់អត់មានឲ្យនៅសល់ទេៗ

ប្រុញៈ ពេលហ្នឹង អូ! ទំនប់ហ្នឹងប្រហែលជាទំហំប៉ុន្មានដែរអ្នកមីង? បណ្ដោយអី?

សារិនៈ មិនដឹង! បើថាទំនប់នេះ ទទឹងបាតក្រោមរបស់វា ១៥ម៉ែត្រ ឡើងលើ៧ម៉ែត្រអីទេខ្ញុំភ្លេចហើយទេ អាទំនប់ហ្នឹង ....

ប្រុញៈ ទទឹងវាប៉ុន្មាន?

សាវីនៈ ទទឹងបាតក្រោមហ្នឹង១៥ម៉ែត្រ លើហ្នឹងប្រហែលជា ៧-៨ម៉ែត្រ អាខ្នងលើរបស់វាហ្នឹង តិចដែរទេណាស់ ពីព្រោះវាស់ជីកឲ្យដែលហ្នឹង ។

ប្រុញៈ ចុះនៅនោះអត់ដឹងប៉ុន្មានម៉ែត្រទេអ្នកមីង?

សាវីនៈ ធំ ទំនប់ត្រពាំងថ្មធំជាងនៅនេះ ។

ប្រុញៈ ធំជាង?

សាវីនៈ ដូចជាបាតក្រោមហ្នឹង២០ម៉ែត្រអីហ្នឹង ខ្ញុំអត់ច្បាស់ទេ ។ អីចឹងណាស់ បើអីចឹងសួរគេបន្ថែមទៀតទៅ ខ្ញុំអត់ច្បាស់ទេ ។

ប្រុញៈ អ្នកមីងធ្វើនៅហ្នឹងយូរទៅ នៅត្រពាំងថ្មហ្នឹង?

សាវីនៈ មិនយូរប៉ុន្មានទេ ខ្ញុំទៅប្រហែលជារយៈពេល១ខែ ឬ២ខែហ្នឹងត្រលប់មកវិញ ។ ទំនប់នេះបណ្ដោយ១៣គីឡូពីស្រែសទៅ ។

ប្រុញៈ ១៣គីឡូ!

សាវីនៈ ពីភ្នំកំបោរមកស្រែះវិញហ្នឹងបណ្ដោយ១៣គីឡូម៉ែត្រ ។

ប្រុញៈ ហើយពេលហ្នឹងគេហូបអីគ្រប់គ្រាន់ដែលទេមីង?

សាវីនៈ ហូបគ្រប់គ្រាន់ហ្នឹងដូចគ្នា គ្រាន់តែខ្វះរឿងទឹក ។

ប្រុញៈ ខ្វះទឹក?

សាវីនៈ ហ្នឹងហើយខ្វះទឹកផឹក ។ ជីកខែប្រាំងហ្នឹងអត់មានទឹកផឹកទេ គេឲ្យទៅរែកនឹងបំពង់ឫស្សីដើរតាមក្រឡុកជើងគោ វេទនាណាស់រឿងទឹកនៅសម័យហ្នឹង ។

ប្រុញៈ ទឹកហ្នឹងគេចែកយើងយ៉ាងម៉េចអ្នកមីង?

សាវីនៈ ទឹកហ្នឹង គេចែកដឹកធុងអីហ្នឹង មកចែកឲ្យយើងផឹក ។

ប្រុញៈ ក្នុង១នាក់បានប៉ុន្មានទៅ?

សាវីនៈ ទៅផឹកមួយផ្អែតហ្នឹងឯង រឿងទឹកនេះគឺកំរណាស់ ។

ប្រុញៈ អត់មានតែម្ដង?

សាវីនៈ ២-៣ថ្ងៃទើបគេឲ្យយើងហ្នឹង មុជម្ដង ។

ប៊ុនថនៈ ដល់ពេលអីចឹង មានបណ្ដាលឲ្យឈឺអីទេ អ្នកមីង?

សាវីនៈ ឈឺណាស់ ទៅហ្នឹងឈឺច្រើនណាស់ អត់សូវមានអ្នកណានេះទេ ។

ប្រុញៈ ឈឺច្រើនដោយសារម៉េច?

សាវីនៈ ដោយសារអត់មានទឹក អត់មានទឹកផឹក អត់មានទឹកមុជហ្នឹងណាស់ ។ ទៅហ្នឹងឈឺច្រើនណាស់ មិនសូវបានទៅ ដូចខ្ញុំថា ខ្ញុំរត់ ខ្ញុំមិននៅទេ ខ្ញុំរត់ ។

ប្រុញៈ អ្នកមីងប្រធានកងហើយ ដល់ពេលរត់ គេអត់មានតាមរកទេ?

សាវីនៈ តាមតើ តាម តែរត់ផុតហើយ ផុតហើយ ។ តែបើចាប់បានវិញហ្នឹង គឺគេវ៉ៃចោលហើយហ្នឹង ។

ប្រុញៈ ដល់ធ្វើប្រធានកងហើយ ធ្វើការដូចគេ ហើយហូបដូចគ្នាទៀតនោះ?

សាវីនៈ ធ្វើដូចតែគ្នា ហើយហូបដូចតែគ្នាហ្នឹង ប្រធានកងហ្នឹង ។

ប្រុញៈ ដល់អីចឹង រត់បណ្តោយ?

សាវីនៈ មិនមែនប្រធានកងមិនធ្វើការណា ប្រធានកងហ្នឹងធ្វើការ ជីកដី រែកដី ដៃហ្នឹងឡើងក្រិននេះ មិនទាន់បាត់ក្រិនណាសម័យនោះ ។

ប្រុញៈ ហើយកាលនោះ គេឲ្យជីកប៉ុន្មានម៉ែត្រដែរ?

សាវីនៈ ២ម៉ែត្រដែរ ។

ប្រុញៈ ទូទៅតែម្តង ២ម៉ែត្រហ្នឹង?

សាវីនៈ ទូទៅតែម្តង ១កងហ្នឹង ២ម៉ែត្រម្នាក់ ម្នាក់២ម៉ែត្រ ។ ប្រធានកងក៏២ម៉ែត្រ ។

ប្រុញៈ គេចាប់ផ្តើមធ្វើការពីម៉ោងប៉ុន្មានដល់ម៉ោងប៉ុន្មាន?

សាវីនៈ មិនដឹងគិតពីម៉ោងប៉ុន្មានទេ ។ ពីព្រលឹមដល់ព្រលប់ រួចស្មើរណាឈប់ស្មើហ្នឹង បើនិយាយពីរឿងនេះ ។

ប្រុញៈ លើកដីងតែឲ្យហើយ២ម៉ែត្រហ្នឹងតែម្តង?

សាវីនៈ ហ្នឹងហើយដឹងថាហើយ២ម៉ែត្រហ្នឹង បើមិនហើយ គ្រាន់តែបើហើយហ្នឹង សំរាកទៅគឺក្រោកពីយប់ហើយ ទៅបង្ហើយទៀត ពីព្រោះធ្វើការគ្មានម៉ោងកំណត់ឈប់ទេ ។

ប្រុញៈ គេអត់មានដាក់ពិន័យរឿងធ្វើអត់ហើយណាអ្នកមីងនេះ?

សាវីនៈ មិនដាក់ទេ តែបើយើងហ្នឹងធ្វើមិនហើយ ស្អែកឡើងយើងធ្វើបន្តទៀត គ្រាន់តែមិនចង់ឲ្យយើងហ្នឹងលួចបន្ទូរបន្ថយគ្នាយើងទៅ ។

ប្រុញៈ អីចឹងនៅហ្នឹង វេទនាតែរឿងអត់ទឹក មីងណាស់?

សាវីនៈ បើទៅហ្នឹង វេទនារឿងអត់ទឹក បើនៅនេះអត់អីទេ ។

ប្រុញៈ ត្រពាំងថ្ម!

សាវីនៈ ហ្នឹងហើយត្រពាំងថ្មវេទនារឿងអត់ទឹក ។

ប្រុញៈ គេបញ្ជូនមកពីណាវិញអ្នកមីង?

សារីនៈ ដឹកទៅពីភូមិ ។

ប្រុញៈ ពីភូមិ?

សារីនៈ ដឹកពីក្នុងស្រុក ពីត្រពាំងថ្មនេះឯង នេះទៅ ។

ប្រុញៈ ដឹកពីក្នុងស្រុកហ្នឹងទៅ?

សារីនៈ ហ្នឹងហើយ ដឹកពីស្រុកហ្នឹងទៅ ។

ប្រុញៈ ហើយគេយកអីដឹកទៅអ្នកមីង?

សារីនៈ ដឹករទេះគោ ។

ប្រុញៈ រទេះគោ ។ ប៉ុន្មានរទេះគោទៅ?

សារីនៈ មិនដឹងប៉ុន្មានទេ ស្រាប់តែឃើញទឹកអីហ្នឹងគេដឹកអីទៅ ។

ប្រុញៈ ហើយឆ្ងាយទេចាប់ពីភូមិហ្នឹងមក?

សារីនៈ ឆ្ងាយដែលហ្នឹង ប្រហែលជា២-៣-៤គីឡូទេដឹង ។

ប្រុញៈ ដឹកទឹក២-៣គីឡូហ្នឹង ដឹករទេះគោ?

សារីនៈ ហ្នឹងហើយ ។

ប្រុញៈ ដល់ពេលអីចឹងរឿងទឹកមួយហ្នឹងយ៉ាប់តែម្តង ឆ្ងាយពេកអីចឹងអត់មានទឹកហូប ។

សារីនៈ អត់មានទឹកហូបទេ ។

ប្រុញៈ ចុះដល់ពេលអ្នកជំងឺឈឺអីចឹងទៅ ដឹកទៅណាវិញទៅមីង?

សារីនៈ មិនដឹងដឹកទៅណាទេ មិនដឹងទេ អារឿងអ្នកជំងឺហ្នឹង មិនដឹងដឹកទៅណាទេ ។

ប្រុញៈ ឈឺស្លាប់ច្រើនទេនៅកន្លែងហ្នឹងអ្នកមីង?

សារីនៈ ដល់ពេលហ្នឹង អារឿងស្លាប់ហ្នឹង អត់ដែលដឹង ។,

ប្រុញៈ គេអត់ឲ្យយើងឃើញ?

សារីនៈ គេអត់ឲ្យយើងឃើញ ពេលឈឺហ្នឹង គេដឹកចេញទៅ ។

ប្រុញៈ ប៉ុន្តែដឹងថាឈឺច្រើនទេ អ្នកមីង?

សារីនៈ ច្រើនឈឺ ។

ប្រុញៈ ឈឺច្រើនដាងកំបោរស្រេសទៀត?

សារីនៈ ឈឺច្រើនដាងកំបោរស្រេស ហ្នឹងហើយ ។ (អត់បានដួសទឹកដាក់បន្តន់ទេដឹង)

ប្រុញៈ ពេលដែលនៅកំបោរស្រេសហ្នឹងមានអ្នកធំៗអីគេចុះមកមើលហ្នឹងញឹកអីទេអ្នកមីង?

សារីនៈ មិនសូវដឹងទេ ។

ប្រុញៈ ចុះតាវ៉ាល់? តាវ៉ាល់គាត់ចុះមក?

សារីនៈ តាវ៉ាល់យូៗហ្នឹងមកម្ដង ដូចទំនប់នេះ គាត់មកម្ដង ឃើញមុខរបស់គាត់ហ្នឹងម្ដង ។ ១ដង-២ដង ដូចវាយូរណាស់ហើយមិនបានដូចជាចាប់អារម្មណ៍ ។ ដូចថាបំភ្លេចៗ ដូចថាមិនភ្លេច ដូចថានៅតែឃើញ នៅជិតៗនេះឯង ។

ប្រុញៈ ដូចថាវាមិនបានចាំជាក់លាក់តែម្ដង ។

សារីនៈ ហ្នឹងហើយ មិនបានចាំជាក់លាក់ ច្បាស់ ។

ប្រុញៈ ប៉ុន្តែពេលធ្វើនៅទំនប់ហ្នឹង គេផ្សេងៗគេធ្វើនៅទំនប់ហ្នឹងយូរទេ អ្នកមីង? ធ្វើនៅ..?

សារីនៈ ធ្វើមួយរួចៗ ។

ប្រុញៈ ធ្វើរួចហ្នឹងប្រហែលជាប៉ុន្មានខែប៉ុន្មានឆ្នាំទៅនៅហ្នឹង?

សារីនៈ ទេ ដល់ពេលគ្នាច្រើនអីចឹង ដូចមិនសូវយូរទៅ មិនដល់ឆ្នាំទេ ដូចជា៤-៥-៦ខែ គឺអាចរួច ពីព្រោះលើកលឿនណាស់ មិនមែនលើកយូរទៅណាស់ ទំនប់នេះ ប្រហែលជា លើក៣-៤ខែនេះឯង ។

ប្រុញៈ ទំនប់កំបោរស្រេសហ្នឹង?

សារីនៈ ហ្នឹងហើយ ពីព្រោះមិនមែនគ្នាតិចទេណាស់ រាប់ពាន់នាក់ណាស់ រាប់ម៉ឺនដងណាស់ យើងមិនដឹង យើងថារាប់ពាន់ទៅចុះ រាប់ពាន់នាក់ទៅចុះ ។ តែអានោះ ខ្ញុំទៅមិនសូវបាន យូរទេ មិនបានចប់ទេ ។

ប្រុញៈ ត្រពាំងថ្ម?

សារីនៈ មិនបានចប់ការងារទេ ខ្ញុំរត់មកវិញ ។

ប្រុញៈ ទៅហ្នឹង វិន័យរបស់គេហ្នឹងតឹងទេអ្នកមីង?

សារីនៈ ទេ អារឿងតឹងហ្នឹងវាតឹងហើយ គេមិនឲ្យទៅណាទៅនីទេ ។ រត់ហ្នឹង គឺលួចរត់ហើយ គេក៏លួច យើងក៏លួចទៅ ។

ប្រុញៈ ចុះដល់ពេលសំរាក សំរាកនៅកន្លែងណាដែរ?

សារីនៈ សំរាកនៅកន្លែងធ្វើការហ្នឹង ។ កន្លែងធ្វើការនៅណា នៅត្រង់ហ្នឹងហើយ ។ គេធ្វើជារោងជាអីឲ្យយើងហ្នឹងទៅ ប្រក់ស្បូវ ពីដើមហ្នឹងមានតែស្បូវហ្នឹង អត់មានសង្ក័សីអីទេ ។ ពេលគេធ្វើរួចហ្នឹង ដូចរោងទាអីចឹង ។

ប្រុញៈ ចុះដល់ពេលភ្លៀងអី?

សាវីនៈ	ពេលភ្លៀងអីហ្នឹង ជិតដែរ ។ គ្រាន់តែដេលផ្ទាល់ហ្នឹងដី ក្រាលកន្ទេលហើយដេកផ្ទាល់នៅហ្នឹងដីហ្នឹង ។

ប្រុញៈ	ហើយនៅហ្នឹងមានគេរៀបចំការអីទេ ដូចនៅនេះអីដែរទេ?

សាវីនៈ	មានតើ ។ កាលដែលទំនប់នេះចប់ គេរៀបការដែលតើ រៀបការប៉ុន្មានគូទេ ៧០គូ ។

ប្រុញៈ	៧០គូ!

សាវីនៈ	៧០ ឬ ៣០គូទេ ខ្ញុំភ្លេចទៅ បើមិន៣០ទេក៏៧០ដែរ ។

ប្រុញៈ	អាហ្នឹងពេលធ្វើចប់ទំនប់ហ្នឹងភ្លាម?

សាវីនៈ	ហ្នឹងហើយពេលចប់ទំនប់ហ្នឹងភ្លាម គេស្នើរគ្នាសុំរៀបការទៅ ចាប់ដៃគ្នាទៅ ។ ទេ ដឹងអានេះ ៧០គូ កាលអាជិតចប់ហ្នឹង វាភ្លេចដែលទៅ ។

ប្រុញៈ	ធ្លាប់មានដល់៧០គូដែលនៅហ្នឹងអ្នកមីង?

សាវីនៈ	មាន ក៏មិនដឹងថាយើងហ្នឹងជិតចប់ហ្នឹង ។ អាឆ្នាំយើងជិតចប់ហ្នឹង មិនដឹងថាចាប់ដៃរបស់យើងជិត៧០គូនៅសាលាឃុំនេះ ៧០គូ ៧២គូ អីទេកាលហ្នឹង ។

ប្រុញៈ	គេដែលបង្ខំយើងទេអ្នកមីង? គេដែលបង្ខំឲ្យការទេ?

សាវីនៈ	មានបង្ខំដែរ ។

ប្រុញៈ	មានដែរ?

សាវីនៈ	មាន ។

ប្រុញៈ	មានហ្នឹងដល់ប៉ុន្មានគូដែរ?

សាវីនៈ	មាន ២០-៣០គូ ដូចថាពួកយោធាចង់បាននារីចល័តហ្នឹងទៅ ។ យើងថាយើងអត់យកគេបង្ខំឲ្យចាប់ដៃគ្នាអីទៅ ។

ប្រុញៈ	ចុះបើសិនជាយើងអត់ការម៉េចដែរទៅអ្នកមីង?

សាវីនៈ	បើអត់ការ គេវ៉ៃយើងចោលទេដឹង ម៉េចដែរអត់ដឹងរឿងហ្នឹដែរហ្នឹង ។ កាលខ្ញុំហ្នឹងគេសួរគេស្នើរដែរ តែខ្ញុំថាខ្ញុំអត់យក ។ ខ្ញុំហ្នឹងចល័តគ្នាឯង ។

ប្រុញៈ	គេអត់ថាអីទេមីង?

សាវីនៈ	គេអត់ថាអីដែរ ។ ដល់គេសួរទៅ គេស្នើរហ្នឹង ខ្ញុំថាអត់ទាន់យកទេ ទាល់តែ៣ឆ្នាំទៀត ។ កាលនោះឈ្មោះតាអី ឈ្មោះតាស៊ីម ។

ប្រុញៈ	តាស៊ីមអ្នកបង្ខំអ្នកមីង?

សារីនៈ គាត់អ្នកសួរ អ្នកចាស់អ្នកទុំនៅនោះ ដូចថាបន្ទាប់ពីគាវ៉ាល់ហ្នឹងមក គាត់ហ្នឹងហើយ ។ គេសួរទៅដូចថាប្រធានកងយុវជនគេស្នើទៅ ខ្ញុំថាខ្ញុំអត់យកទេ ខ្ញុំថាអីចឹង ។ បានគេសួរ ថា កាលណាបានយក ខ្ញុំថាទាល់តែ៣ឆ្នាំទៀត ។ ៣ឆ្នាំទៀត គេថា៣ឆ្នាំទៀតហ្នឹង ក៏គេ នៅចាំដែរ ។

ប៊ុនថនៈ គាត់នៅភូមិជាមួយហ្នឹងដែរមីង?

សារីនៈ អត់ទេ! អ្នកនៅឆ្ងាយប៉ុន្តែស្គាល់គ្នា ។

ប៊ុនថនៈ អត់ស្អាត?

សារីនៈ (សើច)

ប្រុញៈ ដល់ពេលហ្នឹងគាត់ដើរសួរទូទៅគ្នាតែម្តងមីង?

សារីនៈ គាត់ដើរសួរដូចថា អូនឯងស្រឡាញ់ពីណាទៅ ហើយគេយក ចាប់ដៃគ្នាទៅ បើថាយល់ព្រមទាំងសងខាង ថាខាងស្រីក៏យល់ព្រម ហើយអូនឯងហ្នឹងក៏យល់ព្រម ។ កាលនោះ ដូចអត់សូវបាននិយាយគ្នាប៉ុន្មានទេ យើងពិភាក្សាគ្នាយើងទៅដូចថា យើងស្រឡាញ់ទៅ បានបានទៅ ។ បើថាទៅឲ្យស្នើរ បង្ខំហ្នឹង គេបង្ខំខ្លះដែរតែយើងហ្នឹង អត់យក ។ បានតានោះ គាត់សួរខ្ញុំខ្លះដែលថា កាលណាមិត្តឯងយក ខ្ញុំមានពាក្យម្យ៉ាង ខ្ញុំថាខ្ញុំមិនទាន់ ធ្វើការជូនអង្គការគ្រប់ជ្រុងជ្រោយ ខ្ញុំអត់ទាន់យល់ ។

ប្រុញៈ ដល់ពេលឆ្លើយអីចឹងបានរួចខ្លួន ។

សារីនៈ ឆ្លើយអីចឹងបានរួចខ្លួន បើមិនឆ្លើយអីចឹងទេ គេបង្ខំយើងដឹងយ៉ាងម៉េចទេ ។

ប្រុញៈ ហើយអីចឹងពេលដែលគេបង្ខំហ្នឹងពេលណាដែលអ្នកមីង? ពេល...?

សារីនៈ ពេលដែលគេសួរយើងហ្នឹង យើងថាអត់យកហ្នឹង គេបង្ខំសួរយើងហ្នឹងហ គេសំឡុតយើងម៉េច អាហ្នឹងរឿងគេ ខ្ញុំមិនសូវដឹងទេ គ្រាន់តែឮគេថា...

ប្រុញៈ ដឹងថាហេតុអ្វីបានគេបង្ខំទេអ្នកមីង?

សារីនៈ បង្ខំឲ្យយើងហ្នឹងយកទៅពីព្រោះគេហ្នឹងទាហាន គេធ្វើកាទៅវាល្អទៅ ម៉េចទេ ខ្ញុំមិនសូវដឹង រឿងគេទេ ។ អាហ្នឹង ខ្ញុំដឹងតែរឿងខ្លួនយើង ដល់ទៅរឿងគេហ្នឹង ខ្ញុំមិនសូវដឹងទេ ។

ប្រុញៈ ចុះកាលនៅត្រពាំងថ្មហ្នឹង គេមានបង្ខំទេអ្នកមីង?

សារីនៈ កាលនៅត្រពាំងថ្ម ដូចខ្ញុំថាអីចឹង ពេលយើងស្រឡាញ់គ្នាហ្នឹង គេស្នើរគ្នាទៅ បើថាមិន យកទៅ ក៏ហីទៅ រួចគ្នាទៅ ។ ជួនកាលគេប្រកាន់ថាពួករំដោះចាស់ ១៧មេសា

គេយក១៧ មេសាអីចេះទៅណាស់ ដូចគេអ្នករំដោះចាស់ហ្នឹង គេយកអ្នករំដោះចាស់ទៅណាស់ គេនិយាយថាអីចេះណាស់ៗ ដល់ពេលគេថាអីចុះទៅ ដូចអាខ្លះគេស្មើរគ្នាទៅ អាខ្លះបានទេ ខ្លះមិនបានទៅ ខ្លះក៏យកទៅ ខ្លះក៏អត់យកទៅៗ តាមដែលយើងស្រឡាញ់និងមិនស្រឡាញ់ទេៗ កាលហ្នឹងខ្ញុំនៅកុមារទេ ១៧-១៨អីទេ មិនទាន់អាយុច្រើនៗ

ប្រុញៈ ពេញស្អាត!

សាវីនៈ (សើច) គេសួរខ្ញុំថាអត់យក ហើយដល់ក្រោយមកហ្នឹង ពេលជិតចប់ហ្នឹង គេមកសួរខ្ញុំ ខ្ញុំថាខ្ញុំអត់យកទេៗ កាលនោះមកនៅភូមិយើងហើយ ចេញពីចល័តមកនៅភូមិហើយ ខ្ញុំថាខ្ញុំអត់ទាន់យកទេៗ ថាមិត្តឯងនៅដល់ណាទៀត ដល់ពេលនោះពួកនិរតីមកហើយណាស់ ពួកចុងក្រោយ ហ្នឹងហើយៗ មើលតែការបានប៉ុន្មានហ្នឹង យើងភ្ជុំបិណ្ឌ គេការថ្ងៃភ្ជុំបិណ្ឌ ថ្ងៃដាច់ភ្ជុំបិណ្ឌហើយ គេចាប់ដៃ៧០គូ ឬក៏៣០គូ ខ្ញុំភ្លេចដែលហើយ វា២កន្លែង វា២ដង គេចាប់ដៃគ្នាៗ ចាប់នៅសាលាឃុំនេះម្ដង

ប្រុញៈ នៅកំបោស្រេះ?

សាវីនៈ នៅកំបោស្រេះនោះ ២ដងៗ ដល់ពេលគេសួរទៅ ខ្ញុំថាអត់យកទេ គេថាមិត្តឯងហ្នឹងនៅដល់ណាទៀតៗ មិត្តឯងហ្នឹងយកទៅ មិត្តឯងហ្នឹងចាស់ហើយ ស្អីៗណាទេ ខ្ញុំថា ខ្ញុំអត់ទាន់ចង់បាន ខ្ញុំធ្វើការងារ អត់ទាន់បំពេញកិច្ចការជូនអង្គការបានចប់ចុងចប់ដើមទើប ខ្ញុំទើបខ្ញុំមិនទាន់យកៗ ថាអីចឹងទៅ បានខ្ញុំហ្នឹងផុតខ្លួន បើមិនអីចឹងទេ បង្ខំតែមែនទែន ដែលហ្នឹង បង្ខំឲ្យយកដែរហ្នឹងៗ

ប្រុញៈ ខ្ញុំសរសើរអ្នកមីងចេះរកនឹកឃើញ ...

សាវីនៈ ចុះគេបង្គាប់យើងថាអីចឹងៗ

ប្រុញៈ ចេះនឹកឃើញពាក្យហ្នឹងខំអីហ្នឹង បើមិនស្រួលអីហ្នឹង គេសម្លាប់យើងចោលបាត់ៗ

សាវីនៈ ហ្នឹងហើយៗ

ប្រុញៈ ចេះរកនឹកឃើញ បំរើអង្គការ ទុកបំរើអង្គការអីហ្នឹង

សាវីនៈ ពីព្រោះគេបង្គាប់ឲ្យយើងហ្នឹងថាអីចោះឯង យើងអត់ទាន់យកហ្នឹង យើងថាអីចោះតាមគេអីចឹងៗ

ប្រុញៈ អូ! គេប្រាប់ឲ្យថាអីចឹងៗ

សាវីនៈ ចាស! បើយើងហ្នឹង អត់ទាន់យកហ្នឹង យើងឆ្លើយទៅ ថាខ្ញុំមិនទាន់ ពីព្រោះខ្ញុំមិនទាន់ធ្វើ ការជូនអន្តការបានចប់ចុងចប់ដើម ធ្វើការងារជូនអន្តការចប់ចុងចប់ដើមទើបខ្ញុំយក ។ បាន្សូចខ្លួនទៅ បើមិនអីចឹងបានគេអត់បង្ខំ យើងបានទេ. រួចខ្លួនមួយពេលនោះទៅ ។

ប្រុញៈ ចុះបើអ្នកអត់នឹកឃើញអីចឹង មិនគេយកទៅសម្លាប់ហើយ?

សាវីនៈ អត់នឹកឃើញអីចឹងគេយកទៅទៅ យកទាំងមិនពេញចិត្តទៅ ក៏មាន យកតែគេទៅ ខ្ញុំមិនដឹងដែរ ។

ប្រុញៈ ចុះដល់ពេលមកនេះ គេអត់ដែលបង្ខំទៀតទេមីង?

សាវីនៈ អត់ទេ ដល់ពេលនោះទៅចប់ទៅ សម័យនោះបង្ខំហ្នឹងបង្ខំអាពេលជិតចប់ហើយនោះឯង ។

ប្រុញៈ បង្ខំហ្នឹងបង្ខំជិតចប់នៅត្រពាំងថ្មឬនៅ?

សាវីនៈ ទេ! បង្ខំពេលវៀតណាមជិតចូលមកហើយហ្នឹង គេបង្ខំ ..

ប្រុញៈ គេបង្ខំមួយសារទៀត?

សាវីនៈ បង្ខំមួយសារទៀត គេសួរទៀត គេបង្ខំមួយសារទៀត ។

ប្រុញៈ ពេលហ្នឹងអ្នកមីងនៅឯណាវិញ? នៅ?

សាវីនៈ នៅប៉ោយព្រីង ។

ប្រុញៈ នៅប៉ោយព្រីង?

សាវីនៈ ហ្នឹងហើយនៅប៉ោយព្រីង គេជម្លៀសទៅនៅប៉ោយព្រីង អត់មាននៅនេះទេ ។

ប្រុញៈ ពេលមកប៉ោយព្រីងហ្នឹង ចេញពីត្រពាំងថ្មហ្នឹងមកអ្នកមីង?

សាវីនៈ ចាំមើលណាស់ ពេលដែលនេះ យើងចេញពីភូមិនេះទៅ ទៅនៅភ្នំកូនដំរី ហើយដល់ចេញពីភ្នំកូនដំរី គេឲ្យនៅស្រែស ដល់បានត្រលប់ពីស្រែស ក្រោយមកហ្នឹង គេឲ្យមកនៅភូមិប៉ោយព្រីង

ប្រុញៈ អត់ទាន់ទៅនៅត្រពាំងថ្មទេ?

សាវីនៈ អានោះទៅហើយ តែឪពុកម្តាយនៅភូមិហ្នឹងឯង ។

ប្រុញៈ អ្នកមីងនិយាយប្រាប់ខ្ញុំថាអ្នកមីងទៅកំបោរស្រែស អ្នកមីងហើយថាទៅធ្វើនៅ ....

សាវីនៈ នៅត្រពាំងថ្ម ។

ប្រុញៈ ប៉ុន្តែទីស្នាក់ការដែលអ្នកមីងនៅ?

សារីនៈ នៅភូមិប៉ោយព្រីង ។ មុនដំបូងដូចខ្ញុំអ្នកប្រាប់ណាស់ មុនដំបូងគេជម្លៀសចេញទៅហ្នឹង គេឲ្យទៅនៅភ្នំកូនដំរី...

ប្រុញៈ កូនដំរី!

សារីនៈ ដុតពីកូនដំរីទៅ គេឲ្យទៅនៅស្រែស ដល់ពេលគេជម្លៀសពីស្រែសទៅ គេឲ្យទៅនៅប៉ោយព្រីង ដល់ឲ្យប៉ោយព្រីងគេឲ្យយើងហ្នឹងចេញចល័តហើយ...

ប្រុញៈ ហើយដល់ធ្វើការ ធ្វើការនៅត្រពាំងថ្មអីហ្នឹង?

សារីនៈ ហ្នឹងហើយ! អាហ្នឹងយើងរួចពីកំបោ ត្រពាំងស្រែសរួចបានទៅត្រពាំងថ្មហ្នឹងក្រោយ ។

ប្រុញៈ អូ! យល់ហើយ ។ ហើយដល់ពេលដែលអ្នកមីងធ្វើនៅត្រពាំងថ្មហ្នឹងបានតែ ប៉ុន្មានខែទេ?

សារីនៈ នៅនោះអត់បានយូរទេ ខ្ញុំអត់បានធ្វើទំនប់នោះរួចទេ ។

ប្រុញៈ ហើយទៅអ្នកមីងហ្នឹងមកភូមិវិញម៉េចដែរអ្នកមីង?

សារីនៈ ខ្ញុំរត់មកភូមិ ។

ប្រុញៈ មកភូមិវិញហ្នឹងគេអត់តាមចាប់យើងទេអ្នកមីង?

សារីនៈ តាមដែរ តែប្រធានភូមិអីជួយលាក់ជួយអីហ្នឹងបាននៅ បាននៅ ។

ប្រុញៈ បាននៅរហូតទៅ?

សារីនៈ បាននៅរហូត ដល់នៅរហូតមិនបាន គេឲ្យយើងហ្នឹងចល័តទៅទៀតគេឲ្យយើងហ្នឹងទៅធ្វើស្រែប្រាំងនៅកៀនស្វាយ ចុះទៅក្រោមនោះ ។ មិនបាននៅទេ កាលហ្នឹងចល័តរហូត កាលហ្នឹងផ្ទះនៅមិនបានយូរ ចល័តក៏មិនបានយូរ ម្ល៉េះហើយលួចមកផ្ទះហ្នឹងណាស់ ។ នឹកម៉ែនឹកឪហ្នឹង លួចមកផ្ទះ លួចមកផ្ទះ ។

ប្រុញៈ ពេលមកផ្ទះហ្នឹងគេធ្វើអីនៅផ្ទះដែរអ្នកមីង?

សារីនៈ ពេលនៅផ្ទះហ្នឹងមានធ្វើអី ពេលហ្នឹងយើងទៅធ្វើការទៅ ធ្វើចំការ ដកសំណាបស្ទូងអីទៅ បើខែច្រូតទៅ យើងហ្នឹងច្រូតទៅ ស្ទូងដក ខែធ្វើចំការ ក៏ធ្វើចំការទៅ ។ ប្រធានភូមិអីហ្នឹង ជួយលាក់ជួយពួកខ្លះទៅណាស់ នេះណាស់ ។

ប្រុញៈ ធ្វើស្រែចំការ?

សារីនៈ ហ្នឹងហើយ ។

ប្រុញៈ ហើយគេបង្ខំឲ្យអ្នកមីងហ្នឹងរៀបការមួយសារទៀត?

សារីនៈ លើកក្រោយទៀត អាជិតចប់នោះឯង ។

ប្រុញៈ ប៉ុន្តែនៅក្នុងអំឡុងហ្នឹងអ្នកមីងរស់នៅជាមួយ...?

សាវីនៈ រស់នៅជាមួយនឹងឪពុកម្តាយ ។ នៅជាមួយនឹងឪពុកម្តាយមែនតែគេមិនឲ្យនៅជាមួយនឹងឪពុកម្តាយទេ គេឲ្យនៅផ្សេងទៅទៀត មានយុវជននៅតាមកងទៅទៀត ។ ម្តាយឪពុកនៅភូមិដដែលនៅជោយព្រីងទៅ ហើយពួកខ្ញុំហ្នឹងនៅតាប៉ែននោះ ។ នៅចេញពីភូមិហ្នឹងទៅនៅភូមិតាប៉ែន ត្រង់នេសនេះ ។ គេចល័តយុវជននោះ ថាគេបង្ខំឲ្យការអីហ្នឹង ខ្ញុំថាខ្ញុំអត់យកទេ ។

ប្រុញៈ កាលហ្នឹងគេបង្ខំប៉ុន្មានគូទៅអ្នកមីង?

សាវីនៈ ខ្ញុំដូចជាមិនច្បាស់ ។

ប្រុញៈ ហើយបានការទេ កាលហ្នឹងអ្នកមីង? គេផ្សេងៗណាស់? ការប៉ុន្មានគូ?

សាវីនៈ ការ! ដូចថាខ្ញុំមិនចាំ មិនដឹងថាការ៣០គូ សាលាឃុំ៧២គូទេណាស់ វាភ្លេច ។ វា២ដងវាការ២ដងណាស់ ។ មិនដឹងថាអានេះ៧០គូ មិនថាអានេះ៧០ អានេស៣០វា២ដងណាស់ ។ ឆ្នាំនោះវាការនៅនេស នៅកំបូល នៅកណ្តាលវានេះឯង ។ ការទៅគេការចាប់ដៃគ្នាទៅ ខ្ញុំមិនបានឃើញទៅទេ មិនដឹងទេ គេការចាប់ដៃរបៀបម៉េចទេ មិនដែលបានឃើញទេ ។ គេថាគេការ មិនដែលឲ្យយើងហ្នឹងឃើញ ។,

ប្រុញៈ ដល់ពេលមកភូមិហ្នឹង ហូបគ្រប់គ្រាន់ទេមីង?

សាវីនៈ អត់គ្រប់គ្រាន់ទេ នៅក្នុងភូមិនោះ ។

ប្រុញៈ ម៉េចចឹងអ្នកមីង?

សាវីនៈ នៅតាមភូមិហ្នឹងអត់ហូបគ្រប់គ្រាន់ទេ ។ ក្រោយហ្នឹង៣កំប៉ុង ១ឆ្នាំងខ្លះ ។

ប្រុញៈ ៣កំប៉ុង ។

សាវីនៈ ៣កំប៉ុង១ឆ្នាំង ។

ប្រុញៈ បបរអីចឹង?

សាវីនៈ បបរ! ទឹករាវខ្លូក ។

ប្រុញៈ យើងគ្នាប៉ុន្មាននាក់ទៅម៉ាខ្ទះហ្នឹង?

សាវីនៈ ទេ! មិនដឹងថាប៉ុន្មាននាក់ទេ ម្នាក់បានម៉ាកូនវែកប៉ុណ្ណេះណាស់ ទឹកទទេរណាស់ ។ មានអង្ករមួយគ្រាប់ៗមិនស្មើរហ្នឹងទឹកលេងចានផង ទាបបបរដែលគេលក់ក្រវាត់ចោលសព្វថ្ងៃនេះផង ។ វេទនាណាស់បើនិយាយពីរឿងកាលហ្នឹង វេទនា ។

កាលនៅចល័តទៅ វាមិនសូវអត់ណាស់ សុទ្ធតែបានស៊ីឆ្អែត ហើយដល់ពេលទៅចល័តទៅវាអត់បានស៊ីឆ្អែត ដល់ពេលចល័ត ហើយដល់ពេលទៅដល់ភូមិហ្នឹងវេទនាណាស់ ។

ប្រុញៈ ដល់អ៊ីចឹងចង់នៅចល័តឬមួយចង់នៅភូមិ?

សាវីនៈ ទេ ចង់នៅចល័តផង ចង់ថា បើថាអត់ឃ្លាតអត់មានស៊ីចង់នៅតែជាមួយនឹងឪពុកម្ដាយហ្នឹង បើមានមិនមាននៅជាមួយនឹងឪពុកម្ដាយហ្នឹងស៊ីដំឡូង ស៊ីដើមចេកអីហ្នឹង ចេះតែស៊ីទៅ ចេះតែរស់បានស៊ីទៅ ។ ដំឡូងមី ដំឡូងជ្វាយើងហ្នឹង ចេះតែដាំបានស៊ីទៅនៅជាមួយនឹងគាត់ទៅ ។

ប្រុញៈ ជំនាន់ហ្នឹងមានវត្តអីដែរឬមួយក៏ម៉េចដែរអ្នកមីង?

សាវីនៈ អត់មានទេ ។

ប្រុញៈ គេអត់ឲ្យមានវត្តទេ?

សាវីនៈ អត់មានវត្តទេ ។

ប្រុញៈ វត្តគេឲ្យធ្វើអីវិញ?

សាវីនៈ វត្តនោះ កាលនោះវត្តមិនដឹងធ្វើអីទេ ។ វត្តព្រះនេតព្រះ មិនដឹងថាធ្វើអី មិនដឹងរឿងសោះហើយនេះ ។

ប្រុញៈ ចុះលោកសង្ឃអីម៉េចដែរ?

សាវីនៈ លោកសង្ឃហ្នឹងគេផ្សឹក ។

ប្រុញៈ គេផ្សឹក? គេចាប់ផ្សឹក?

សាវីនៈ គេចាប់ផ្សឹក បោះស្បង់អីហ្នឹង ក្រវាត់ចោលខ្លួនយើងទៅណាស់ ។ អាចាំសម័យនោះដឹងស្រាប់ហើយតើ ។

ប្រុញៈ ចុះ ខ្ញុំដូចជាអស់អីសួរអ្នកមីងហើយ ។

សាវីនៈ សួរនេះអត់ដឹងខុសត្រូវទេ និយាយនេះ ។

ប្រុញៈ អត់អីទេអ្នកមីងសួរហ្នឹងគ្រាន់តែសួរចង់ស្រង់ជាឯកសារដើម្បីឲ្យកូនចៅជំនាន់ក្រោយមើលថាសម័យនោះគេធ្វើអី អីខ្លះអីចឹងណាស់ ។ ដូចថាបបរម៉ា....

សាវីនៈ ម៉ាខ្ទះគ្នាតពាក់ប៉ុង ។

ប្រុញៈ ហើយយើងហូបមិនឆ្អែតអីហ្នឹងណាស់ អត់ទឹកមុជអីអត់ហូបអីចឹងណាស់ ។ សូម្បីតែទឹកហូបក៏អត់គ្រប់គ្រាន់អីចឹងណាស់ ។

សាវីនៈ អត់គ្រប់គ្រាន់ ជួនកាលគ្រប់គ្រាន់ទេ ហើយជួនកាលទៅអត់មានទេ។ បើថាទៅនោះអត់មានទេ បើថានៅនេះមាន សំបូរទឹកនៅជិតមានបឹងអីនោះ ហើយទៅនោះ អត់មានទេ។

ប៊ុនថនៈ អីចឹងអ្នកមីង ក្រោយមកហើយបានមីងរៀបការមីង?

សាវីនៈ ខ្ញុំរៀបការនៅឆ្នាំ១៩៨២។

ប្រុញៈ ការក្រោយទេ!

សាវីនៈ ការក្រោយទេ។

ប៊ុនថនៈ គ្រួសាររបស់អ្នកមីងឈ្មោះអីដែរអ្នកមីង?

សាវីនៈ ឈ្មោះ ទី សុវណ្ណ។

ប្រុញៈ គាត់ធ្វើគ្រូ?

សាវីនៈ ហ្នឹងហើយធ្វើគ្រូ។

ប្រុញៈ ធ្វើតាំងពីមុនមកហ្នឹង អ្នកមីង?

សាវីនៈ ធ្វើចាប់ពី៧៩មក គាត់ធ្វើគ្រូ ៧៩ ឬ៨៩ ទេ ខ្ញុំភ្លេចហើយ។

ប្រុញៈ ចុះគេអត់ដឹងថាគាត់ហ្នឹងអ្នកចេះអីទេ អ្នកមីង?

សាវីនៈ ចុះ គាត់ហ្នឹងមានទៅចេះអីកាលហ្នឹង គាត់រៀនថ្នាក់ទី៧ ទី៦ កាលហ្នឹង។ គាត់រៀនលើខ្ញុំ កាលហ្នឹង គាត់អាយុច្រើនជាខ្ញុំនោះ។ គាត់៥៤-៥៥ហើយដឹង។ ហ្នឹងហើយ តែស្រុក កំណើតរបស់គាត់នៅនេះដែលហ្នឹង ជាប់សាច់ជាប់ឈាមដែលហ្នឹង។ បងប្អូនដែលហ្នឹង។

ប្រុញៈ បានជួបគ្នានៅ។ អីចឹងខ្ញុំអស់អីសួរទៀតហើយ។

សាវីនៈ ចាស!

ប៊ុនថនៈ សព្វថ្ងៃហ្នឹងមានកូនប៉ុន្មាននាក់?

សាវីនៈ ខ្ញុំមានកូន ៥នាក់។

ប៊ុនថនៈ ៥នាក់។

ប្រុញៈ សុទ្ធតែរៀនទាំងអស់អ្នកមីង?

សាវីនៈ អីឈប់រៀនអស់ហើយ នេះនៅមីមួយនេះ។ មីបងហ្នឹង គេឈប់រៀនថ្នាក់ទី១១ គេឈប់រៀនហើយ អាបងនោះគេប្រលងថ្នាក់ទី១២ ឆ្នាំទៅមិញធ្លាក់។ អាហ្នឹង ឆ្នាំមមី ឆ្នាំមមែទេ គេទៅរៀនដេរជាមួយម្ដាយមីងរបស់គេនៅប៉ោយប៉ែត បាត់ហើយហ្នឹង។

គេប្រលងធ្លាក់ ហើយខ្ញុំថារៀនមួយឆ្នាំទៀតទៅ ធ្លាក់ជាប់ហ្នឹងក៏ដឹងហើយ គេអត់នៅ ។ ហើយក៏ឈប់រៀនទៅ ហើយមីមួយនេះ រៀនថ្នាក់ទី១១ ក៏ឈប់រៀនទៅ ។

ប្រុញៈ តូចនេះ?

សាវីនៈ មីងបង ។ មីនេះថ្នាក់ទី៨ទេ ។ នោះពៅគេ ។

ប៊ុនថនៈ ចុះអ្នកមីងចុងក្រោយ ខ្ញុំសុំសួរទាក់ទងទៅនឹងការយល់ដឹងរបស់មីង ដូចថាសព្វថ្ងៃនេះមានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ហើយនឹងបែកសាវនាការនៅខែហ្នឹង នៅថ្ងៃទី២៨ កាត់ទោសមេដឹកនាំធំៗ៤នាក់ ។ អ៊ីចឹងមីងយល់យ៉ាងម៉េចដែរ ពីតុលាការខ្មែរក្រហមហ្នឹងមីង? តាមចិត្តរបស់មីង?

សាវីនៈ មិនដឹងយល់ថាម៉េចទេនេះ ។ មិនដឹងដាក់ទោសថាម៉េចទេ ។

ប៊ុនថនៈ តាមចិត្តរបស់មីង មីងយល់យ៉ាងម៉េចដែរ? ដូចថត្រឹមត្រូវ ឬមួយក៏គិតថាគួរតែលើកលែងទៅ បំភ្លេចអ៊ីចឹងអ្នកមីង?

សាវីនៈ តាមដែលទឹងហ្នឹងមិនគួរបំភ្លេចទេណាស់ ។

ប៊ុនថនៈ ម៉េចមីង?

សាវីនៈ ដូចថាឈឺចិត្ត អារឿងហូបអត់ឆ្អែតធ្វើការ វាពិបាកវេទនា ទៅតាមដែលទឹងហ្នឹងណាស់ យូរទៅក៏បាត់កំហឹង យូរទៅគួរឲ្យលើកលែង ក៏លើកលែងទៅ ។

ប្រុញៈ ៣០ជាងហើយ?

សាវីនៈ ហ្នឹងហើយ៣០ជាងហើយ ។ វាឆ្អែតឆ្អន់ហើយ ។ ខ្ញុំប្រាប់កូនខ្ញុំថា ម៉ែចល័តរហូតមិនដែលបាននៅស្រុកទេ នៅតិចណាស់ ។

ប៊ុនថនៈ អ៊ីចឹងអ្នកមីងមានអីចង់បន្ថែមទៀតទេ អ្នកមីង?

សាវីនៈ អត់មានទេ ។

ប៊ុនថនៈ អ៊ីចឹង ខ្ញុំសុំអរគុណច្រើនអ្នកមីងណាស់ ។

«ចប់»